**ជំនួយស្មារតី**

# សម្រាប់ការកាត់បន្ថយ និងដោះស្រាយវិវាទ នៅក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា នៅក្នុងប្រទេសកម្ពុជា



បណ្ឌិត សំ ចាន់ធី

វិច្ឆិកា ២០២៤

ឯកសារនេះចងក្រងដោយ **បណ្ឌិត សំ ចាន់ធី** ក្រោមគម្រោងអភិបាលដីធ្លីតំបន់មេគង្គ។
រាល់មាតិកា និងទស្សនៈ ក្នុងឯកសារនេះ គឺជាការទទួលខុសត្រូវរបស់អ្នកស្រាវជ្រាវ
និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយ និងអង្គការអុកស្វាមឡើយ។

ខ្លឹមសារក្នុងឯកសារនេះអាចត្រូវបានអនុញ្ញាតិឲ្យប្រើប្រាស់សម្រាប់ការអប់រំ ផ្សព្វផ្សាយ
និងការស្រាវជ្រាវ ដោយបង្ហាញប្រភពពេញលេញ។ រាល់ការប្រើប្រាស់ត្រូវផ្តល់
ព័ត៌មានដល់អង្គការអុកស្វាមជាមុនសិន។ សម្រាប់ការចម្លង ឬប្រើប្រាស់ឡើងវិញ
ក្នុងផ្នែកណាមួយ ឬការបកប្រែ ឬសម្រួល ត្រូវមានការអនុញ្ញាតិ
ជាលាយលក្ខណ៍អក្សរពីអង្គការអុកស្វាម។

បោះពុម្ព ខែ មិថុនា ឆ្នាំ ២០២៥ ដោយអង្គការអុកស្វាម

# មាតិកា


១. គោលបំណង .......... ១

២. ទំនាស់ ឬវិវាទ .......... ២

៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យា .......... ២

៤. ប្រភេទកិច្ចសន្យាផលិតកម្មកសិកម្មក្នុងប្រទេសកម្ពុជា .......... ៥

៥. ប្រភពនៃវិវាទនៅក្នុងការអនុវត្តកិច្ចសន្យា
ផលិតកម្មតាមកិច្ចសន្យា .......... ៧

៦. ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយវិវាទ
អំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា .......... ៩

៧. ការអនុវត្តការដោះស្រាយវិវាទកិច្ចសន្យា
នៃផលិតកម្មតាមកិច្ចសន្យា .......... ១១

៨. គោលការណ៍គន្លឹះក្នុងការអនុវត្តផលិតកម្ម
កសិកម្មតាមកិច្ចសន្យា .......... ១៦

៩. ក្របខ័ណ្ឌគោលការណ៍កាត់បន្ថយវិវាទ
ក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា .......... ២២

ឧបសម្ព័ន្ធ .......... ២៤

# ជំនួយស្មារតី សម្រាប់ការកាត់បន្ថយនិងដោះស្រាយវិវាទ នៅក្នុងការអនុវត្តផលិតកម្មកសិកម្ម តាមកិច្ចសន្យានៅក្នុងប្រទេសកម្ពុជា

## ១ គោលបំណង

ឯកសារជំនួយស្មារតីនេះមានគោលបំណងបង្ហាញនូវនីតិវិធី និងយន្តការក្នុងការដោះស្រាយទំនាស់ពីការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះផងដែរ ឯកសារនេះក៏បានលើកឡើងនូវកត្តាគន្លឹះមួយចំនួនក្នុងការរៀបចំ និងអនុវត្តនូវកិច្ចសន្យាផលិតកម្មកសិកម្មដែលអាចជួយកាត់បន្ថយនូវទំនាស់ និងជំរុញការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

ឯកសារជំនួយស្មារតីនេះសំដៅជាពិសេសដល់កសិករ សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម សម្ព័ន្ធសហគមន៍កសិកម្មដែលជាភាគីអ្នកផលិត និងក្រុមហ៊ុនឯកជនដែលជាភាគីអ្នកទិញ និងតួអង្គពាក់ព័ន្ធមួយចំនួនទៀតនៅក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្មតាមកិច្ចសន្យា។ តួអង្គនីមួយៗសុទ្ធតែមានតួនាទី កាតព្វកិច្ច និងឆន្ទៈដោះស្រាយទំនាស់ប្រកបដោយតម្លាភាព ភាតរភាព សមធម៌ និងទៀងត្រង់ ដោយតម្កល់នូវផលប្រយោជន៍រួម និងអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ២ ទំនាស់ ឬវិវាទ

**ទំនាស់** គឺជាសេចក្តីទាស់ទែងគ្នាមិនចុះសម្រុងគ្នា ខ្វែងគំនិតគ្នា ការប៉ះទង្គិចគ្នារវាងគោលបំណង ការប្រទូសរ៉ាយរវាងភាគីទាំងឡាយដែលពាក់ព័ន្ធផលប្រយោជន៍ ឬធ្វើឱ្យបាត់បង់កេរ្តិ៍ឈ្មោះ។ តាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពឆ្នាំ១៩៦៨ បានកំណត់ថា **ទំនាស់** គឺជាពាក្យ ដំណើរ  សេចក្តីអំពើដែលទាស់ ដែលផ្ទុយ ដែលទីទៃពីគ្នា។ ដោយឡែក **វិវាទ** មានន័យថា ដំណើរទាស់ទែងគ្នា ដំណើរឈ្លោះប្រកែកគ្នា។ ពាក្យទាំងពីរនេះត្រូវបានប្រើប្រាស់ឆ្លាស់គ្នាទៅវិញទៅមកនៅក្នុងឯកសារនេះ។

ការដោះស្រាយទំនាស់ គឺជាដំណើរការមួយដែលអាចជួយគ្រប់គ្រង កំណត់ ឬដោះស្រាយភាពខ្វែងគំនិតគ្នាដែលកើតមានក្នុងចំណោមរូបវន្តបុគ្គល គ្រួសារ ស្ថាប័ន សហគមន៍ ប្រជាជាតិ ឬអង្គភាពសង្គមណាមួយ។ ទំនាស់សង្គមអាចកើតឡើងដោយសារតែការយល់ឃើញខុសគ្នាទាក់ទងនឹងគុណតម្លៃ សេចក្តីត្រូវការ គោលដៅ ផលប្រយោជន៍ សិទ្ធិ ឬក្តីប្រាថ្នារបស់សមាជិកនីមួយៗនៅក្នុងសង្គម។ នៅក្នុងបរិបទផលិតកម្មកសិកម្មតាមកិច្ចសន្យា ការដោះស្រាយទំនាស់ ឬវិវាទគឺជាដំណើរការក្នុងការគ្រប់គ្រង កំណត់ ឬដោះស្រាយភាពខ្វែងគំនិតគ្នារវាងគូភាគីនៃកិច្ចសន្យាដែលស្ម័គ្រចិត្តអនុវត្តកម្មវិធីផលិតកម្មកសិកម្ម។ ដំណើរការនេះផ្តល់ឧបាស្រ័យចំពោះការខកខាន ការបំពាន ឬការមិនបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ ឬតាមការចែងក្នុងកិច្ចសន្យា បូករួមទៅនឹងអំពើមិនស្មោះត្រង់របស់ភាគីក្នុងការរៀបចំផ្នែកផលិតកម្មកសិកម្ម។

## ៣ ផលិតកម្មកសិកម្មតាមកិច្ចសន្យា

មាត្រា៤ នៃអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា បានកំណត់ថា **ផលិតកម្មកសិកម្មតាមកិច្ចសន្យា** សំដៅដល់ផលិតកម្មកសិកម្មដោយមានការធានាអំពីតម្លៃ បរិមាណ និងគុណភាពផលិតផល ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀតដែលមានការព្រមព្រៀងគ្នាមុនការផលិត។ ម៉្យាងវិញទៀត សៀវភៅណែនាំសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា (ឆ្នាំ២០១៨)[១] បានពន្យល់បន្ថែមថាជា ការរៀបចំជាប់កាតព្វកិច្ចរវាងអ្នកចុះកិច្ចសន្យា (អ្នកទិញផលិតផលកសិកម្មដែលជាទូទៅជាក្រុមហ៊ុន) និង ផលិតករ ឬអង្គការផលិតករក្នុងទម្រង់ជាកិច្ចសន្យា ដោយផ្ទាល់មាត់ឬដោយលាយលក្ខណ៍អក្សរដែលបានចរចាមុនពេលផលិតកម្មចាប់ផ្តើម (ឬនៅដំណាក់កាលដំបូងនៃដំណើរការផលិតកម្ម) ដែលផលិតករប្តេជ្ញាផលិតផលកសិកម្មជាក់លាក់ (អាចស្ថិតនៅក្នុងលក្ខខណ្ឌជាក់លាក់

[១] គំរូកិច្ចសន្យាផលិតកម្មកសិកម្មនៅក្នុងសារាចរណ៍ណែនាំលេខ១៩៦ ស្តីពីពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា https://server.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/64206f8de8574f670bb7c33b6612ae69_1599466990.pdf

ណាមួយ) និងលក់ផលិតផលនោះទៅឱ្យអ្នកចុះកិច្ចសន្យាផ្តាច់មុខ ឬជាអាទិភាព ឬតាមបរិមាណអប្បរមាដែលបានព្រមព្រៀងគ្នា។ ចំណែកឯអ្នកចុះកិច្ចសន្យាត្រូវប្តេជ្ញាទិញផលិតផលនោះ (ផលិតកម្មទាំងអស់ ឬបរិមាណអប្បរមាដែលបានព្រមព្រៀងគ្នា) នៅក្នុងតម្លៃដែលបានព្រមព្រៀងគ្នា ឬតម្លៃដែលបានកំណត់អាស្រ័យលើបែបបទដែលបានព្រមព្រៀងគ្នា ហើយត្រូវផ្តល់ជំនួយផ្នែកបច្ចេកទេស និង/ឬសម្ភារ និង/ឬជំនួយហិរញ្ញវត្ថុទៅដល់កសិករ។

ដោយឡែក **កិច្ចសន្យាផលិតកម្មកសិកម្ម** សំដៅដល់ការព្រមព្រៀងលើអាជីវកម្មផលិតកម្មកសិកម្មដែលបានធ្វើឡើងរវាងភាគីពីរ ឬច្រើនដើម្បីដាក់ឱ្យប្រតិបត្តិការតាមផ្លូវច្បាប់ ហើយត្រូវមានចែងពីលក្ខខណ្ឌតម្រូវនានាជាមុន។ កិច្ចសន្យាផលិតកម្មកសិកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយកិច្ចសន្យានេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី និងច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀតជាធរមាន។ មាត្រា៣១១ នៃក្រមរដ្ឋប្បវេណីចែងថាកិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។ នៅក្នុងកិច្ចសន្យា កាតព្វកិច្ចគឺជាចំណុចស្នូលនៃគំនិត ហើយសំដែងនូវទំនាក់ទំនងតាមផ្លូវច្បាប់ដែលបានចូលរួមជាមួយបុគ្គលពិសេសណាមួយជាមួយបុគ្គលម្នាក់ផ្សេងទៀត តាមរយៈការសន្មត់អំពីកាតព្វកិច្ចពិតប្រាកដមួយដោយគោរពទៅនឹងអ្វីដែលបុគ្គលនោះបញ្ជាក់ជាចុងក្រោយ។

ជាទូទៅ **ភាគីអ្នកផលិត** ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលមានមុខរបរក្នុងផលិតកម្មកសិកម្មមានសិទ្ធិនិងកាតព្វកិច្ចគោរពតាមលក្ខខណ្ឌផលិតកម្មកសិកម្មស្របតាមការព្រមព្រៀង, ដំណើរការផលិតកម្មកសិកម្មស្របតាមរដូវកាលនិងពេលវេលាកំណត់, អនុវត្តបច្ចេកវិទ្យានិងវិធីសាស្ត្រផលិតស្របតាមតម្រូវការរបស់ភាគីអ្នកទិញ, ផ្គត់ផ្គង់ផលិតផលតាមស្របចំណាត់ថ្នាក់ គុណភាព បរិមាណនិងពេលវេលាកំណត់, និងទទួលការទូទាត់តម្លៃផលិតផលស្របតាមតម្លៃដែលបានព្រមព្រៀង។ ភាគីអ្នកផលិតអាចជាបុគ្គល ឬ សហគមន៍កសិកម្ម។ **សហគមន៍កសិកម្ម** សំដៅដល់សហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍកសិកម្ម និងបុរេសហគមន៍អភិវឌ្ឍកសិកម្ម។ សហគមន៍នេះជានីតិបុគ្គលឯកជនមានលក្ខណៈជា សហគ្រាសសេដ្ឋកិច្ចកសិកម្មដែលបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម តាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើម្ចាស់ និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដើម្បីពង្រឹងសមត្ថភាពផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក (មាត្រា៤)[២,៣] ។ សហគមន៍បែបនេះត្រូវទទួលស្គាល់ដោយក្រសួងនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរដែនដីនៅក្នុងទីតាំងរបស់សហគមន៍ទាំងនោះ។ ដោយឡែក **ភាគីអ្នកទិញ** ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលធ្វើអាជីវកម្មទិញផលិតផលកសិកម្មក៏ត្រូវអនុវត្តសិទ្ធិនិងកាតព្វកិច្ចដូចជា គោរពតាមលក្ខខណ្ឌផលិតកម្មកសិកម្មស្របតាមការព្រមព្រៀង, កំណត់យថាប្រភេទទំនិញ បរិមាណ គុណភាព ទីកន្លែងនិងកាលបរិច្ឆេទនៃការប្រគល់ទទួល, ផ្តល់សម្ភារកសិកម្ម ពូជរុក្ខជាតិ ពូជដំណាំ ពូជវារីជាតិ ពូជសត្វ ឥណ

[២] ច្បាប់ស្តីពីសហគមន៍កសិកម្ម ឆ្នាំ២០១៣

[៣] ការបង្កើតសហគមន៍កសិកម្មត្រូវឈរលើគោលការណ៍គ្រឹះដូចជា ១. ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហសមាជិកភាព, ២. ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក, ៣. ការចូលរួមផ្នែកសេដ្ឋកិច្ចដោយសមាជិក, ៤. ស្វ័យភាពនិងឯករាជ្យ, ៥. ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន, ៦. ការធ្វើសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត, និង ៧. ការគិតគូរដល់សហគមន៍។ គោលការណ៍គ្រឹះទាំងនេះត្រូវបានពន្យល់ដោយសង្ខេបនៅក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីសហគមន៍កសិកម្ម ឆ្នាំ២០១៣។

នាជាមុន សេវាបច្ចេកទេសនិងមធ្យោបាយ ឬជំនួយផ្សេងៗដល់ភាគីអ្នកផលិតតាមការព្រមព្រៀងដើម្បីធានាដល់ដំណើរការនិងទទួលបានលទ្ធផលល្អ, ទូទាត់តម្លៃផលិតផលកសិកម្មតាមឯកតាច្បាស់លាស់ និងគុណភាពតាមតម្លៃដែលបានព្រមព្រៀង, និងទូទាត់តម្លៃទំនិញជូនភាគីអ្នកផលិតតាមលក្ខខណ្ឌ និងតាមដំណាក់កាលពេលវេលាកំណត់តាមការព្រមព្រៀង។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ជាស្ថាប័ននាំមុខក្នុងការទាក់ទង សម្របសម្រួល និងផ្តល់សេវាជំនាញតាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីបង្កភាពងាយស្រួលដល់ការអភិវឌ្ឍផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ក្រសួងត្រូវធ្វើការតាមដាន វាយតម្លៃការងារទាំងនេះ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។ បន្ថែមពីលើនេះ **គណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម** ត្រូវបានបង្កើតឡើងដើម្បីជួយរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រក្នុងការលើកស្ទួយផលិតកម្មកសិកម្មតាមកិច្ចសន្យា, ជួយសម្របសម្រួលនិងពង្រឹងនូវសុខដុមនីយកម្មរវាងភាគីនៃកិច្ចសន្យាផលិតកម្មកសិកម្ម, និងធ្វើអន្តរាគមន៍ឬសម្របសម្រួលការខ្វែងគំនិត ឬទំនាស់ដែលលេចចេញពីកិច្ចសន្យាផលិតកម្មកសិកម្មដែល ស្ថាប័នជំនាញពុំអាចដោះស្រាយបាន ឬទំនាស់ដែលមានលក្ខណៈតម្រូវឱ្យមានការដោះស្រាយអន្តរស្ថាប័ន។ គណៈកម្មាធិការនេះត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានតំណាងពីក្រសួងស្ថាប័នផ្សេងទៀតជាសមាជិក ដោយមាននាយកដ្ឋានកសិ-ឧស្សាហកម្មជាជំនួយការ។

ផលិតកម្មតាមកិច្ចសន្យាគឺជាកិច្ចព្រមព្រៀងគ្នាមុនរវាងអ្នកលក់ (អ្នកផលិត ឬកសិករ) និងអ្នកទិញ (អ្នកម៉ៅការ) ក្នុងលក្ខណៈជាដៃគូក្នុងអាជីវកម្មក្នុងការផ្គត់ផ្គង់តាមបរិមាណ និងគុណភាពដែលបានកំណត់ ព្រមទាំងកំណត់អំពីកាតព្វកិច្ចរបស់ភាគីអ្នកទិញ (អ្នកកែច្នៃផលិតផលកសិកម្ម ឬឈ្មួញ) ក្នុងការទទួលទិញទំនិញផលិតផលកសិកម្ម ហើយបំពេញការបង់ប្រាក់តាមការព្រមព្រៀង។ ម៉្យាងវិញទៀត ផលិតកម្មតាមកិច្ចសន្យា សំដៅលើការរៀបចំស្ថាប័នរវាងកសិករ និងអ្នកទិញ នៅក្នុងផលិតកម្មកសិកម្ម និងអាជីវកម្មកសិផល ដោយកសិករយល់ព្រមផ្តល់ជាក់លាក់នូវទំនិញ ឬកសិផលក្នុងបរិមាណ និងស្របតាម ស្តង់ដាគុណភាពដែលបានកំណត់ទុកជាមុន ខណៈពេលដែលអ្នកបញ្ជទិញយល់ព្រមផ្តល់ធាតុចូលផលិតកម្ម ទីផ្សារ និងតម្លៃ។

កិច្ចសន្យាផលិតកម្មកសិកម្ម ផ្តោតជាចម្បងទៅលើភាគីពីរគឺ ភាគី «អ្នកផលិត» ដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការផលិតនូវផលិតផលកសិកម្ម ដែលអាចជាបុគ្គល ឬសហគ្រាសឯករាជ្យ និង ភាគី «អ្នកទិញ ឬអ្នកម៉ៅការ» ដែលប្តេជ្ញាទិញយក ឬទទួលយកការប្រគល់ឱ្យនូវផលិតផល (កសិកផល) ទាំងនោះ ហើយភាគច្រើនជាក្រុមហ៊ុនអាជីវកម្មក្នុងវិស័យកសិកម្ម ដែលធ្វើសកម្មភាពកែច្នៃ ឬទំនាក់ទំនងនិងចែកចាយផលិតផលកសិកម្មតាមទីផ្សារ។ កិច្ចព្រមព្រៀង ឬកិច្ចសន្យានោះ អាចជាផ្នែកមួយនៃប្រតិបត្តិការដ៏ស្មុគស្មាញមួយ។ ជាទូទៅ ភាគីនានាធ្វើកិច្ចសន្យាជាមួយគ្នាមុនពេលចាប់ផ្តើមផលិតកម្ម ហើយកិច្ចសន្យានោះគុណភាពផលិតផលវិធីសាស្ត្រផលិត ពេលវេលា តម្លៃ ការគាំពារ និងមានកិច្ចព្រមព្រៀងផ្សេងៗមួយចំនួនទៀតសម្រាប់អនុវត្តជាក់លាក់ដែលអាចមានសុពលភាពពេញមួយវដ្ត ឬច្រើនវដ្តនៃផលិតកម្ម។ តាមការអនុវត្តជាក់ស្តែង ផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលជោគជ័យ ជាធម្មតាតម្រូវឱ្យភាគីពាក់ព័ន្ធពិនិត្យ និងកែសម្រួលលក្ខខណ្ឌនៃកិច្ចសន្យាជារៀងរាល់ឆ្នាំដើម្បីធានាបាននូវបច្ចុប្បន្នភាព និងដោះស្រាយបាននូវវិវាទដែលអាចនឹងកើតឡើង។

# ៤ ប្រភេទកិច្ចសន្យាផលិតកម្មកសិកម្ម ក្នុងប្រទេសកម្ពុជា

ប្រទេសកម្ពុជាបានអនុវត្តនូវផលិតកម្មកសិកម្មតាមកិច្ចសន្យាជាផ្លូវការ ចាប់តាំងពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្នុងឆ្នាំ២០១១។ តាមការអនុវត្តកន្លងមក ផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានធ្វើឡើងក្នុងទម្រង់និងរូបភាពដូចខាងក្រោម៖

**១. ប្រភេទមជ្ឈការ៖** ជាធម្មតា ភាគីអ្នកទិញធ្វើកិច្ចសន្យាផ្លូវការជាលាយលក្ខណ៍អក្សរជាមួយកសិករម្នាក់ៗ ឬក្រុមកសិករដែលជាទូទៅជាសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្ម សម្រាប់ផលិត និងការផ្គត់ផ្គង់ផលិតផលកសិកម្ម។ ទោះបីជាត្រូវបានចាត់ថ្នាក់ជាផ្លូវការក៏ដោយ កិច្ចសន្យាបែបនេះមិនតែងតែត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាននោះទេ។ លក្ខណៈសំខាន់នៃគំរូនេះ គឺការគ្រប់គ្រងពីលើចុះក្រោម ជាមួយនឹងការគ្រប់គ្រងយ៉ាងតឹងរ៉ឹងលើគុណភាព និងបរិមាណនៃ ផលិតផល។ រចនាសម្ព័ន្ធពីលើចុះក្រោម មានន័យថា អ្វីៗគ្រប់យ៉ាងត្រូវបានរៀបចំដោយភាគីអ្នកទិញ ហើយកសិករគ្រាន់តែធ្វើតាមការណែនាំ និងការបង្គាប់បញ្ជារប៉ុណ្ណោះ។

**២. ប្រភេទពហុភាគី៖** គំរូពហុភាគីនេះ ជាទូទៅពាក់ព័ន្ធនឹងការបណ្ដាក់ទុនរួមគ្នារវាងកសិករ អង្គភាពនិយតកម្ម និងក្រុមហ៊ុនឯកជន ទោះបីជារដ្ឋាភិបាល (ក្នុងភាពជាដៃគូជាមួយវិស័យឯកជន) ពេលខ្លះអាចវិនិយោគនៅក្នុង ផលិតកម្មកសិកម្មតាមកិច្ចសន្យានេះក៏ដោយ។ គំរូបែបនេះពាក់ព័ន្ធនឹងកសិករ និងក្រុមហ៊ុនឯកជន វិនិយោគិន ឬអង្គភាពមិនរកប្រាក់ចំណេញច្រើនជាងមួយ។ អង្គការមិនមែនរដ្ឋាភិបាល និងការិយាល័យផ្សព្វផ្សាយកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យកសិករទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីកិច្ចសន្យា។ ពួកគេផ្ដល់ឥណទាន ដំបូន្មានបច្ចេកទេស ធាតុចូលផលិតកម្ម និងពេលខ្លះជំនួយផ្នែកទីផ្សារបន្ថែម។ កសិករភាគច្រើនជាសមាជិករបស់សហគមន៍កសិកម្មដែលត្រូវបានបង្កើតឡើង មុនពេលមានវត្តមានរបស់ភាគីអ្នកទិញ។

**៣. ប្រភេទអន្តរការី ៖** កសិករ អ្នកប្រមូលទិញ ឬឈ្មួញកណ្ដាល (អន្តរការី) និងភាគីអ្នកទិញ (អ្នកម៉ៅការ)។ គំរូបែបនេះត្រូវបានអនុវត្តជាធម្មតានៅក្នុងប្រទេសកម្ពុជា។ ភាគីអ្នកទិញមិនធ្វើកិច្ចសន្យាផ្ទាល់ជាមួយកសិករទេ ប៉ុន្តែធ្វើកិច្ចសន្យាផ្លូវការ ឬក្រៅផ្លូវការជាមួយអន្តរការី ឬអ្នកប្រមូលទិញទំនិញ ឬ កសិផលជំនួសវិញ។ ដោយឡែក អ្នកប្រមូលទិញបែរជាធ្វើកិច្ចសន្យាក្រៅផ្លូវការជាមួយកសិករមួយចំនួន ដើម្បីផ្គត់ផ្គង់ផលិតផលទៅឱ្យភាគីអ្នកទិញ។ ជាទូទៅ ភាគីអ្នកទិញមិនចង់ចូលរួមដោយផ្ទាល់ជាមួយកសិករក្នុងសកម្មភាពផលិតកម្មទេ។ ភាគីអ្នកទិញអាចជាអ្នកកែច្នៃផលិតផល ឬពាណិជ្ជករធំ (ឧ. ផ្សារទំនើប)។ ទំនិញ ឬកសិផលដែលភាគីអ្នកទិញទិញជាចម្បងគឺបន្លែ អង្ករ ម្រេច និងផលិតផលសត្វដូចជាសាច់មាន់ សាច់ជ្រូក សាច់គោ និងស៊ុតជាដើម។

**៤. ប្រភេទក្រៅប្រព័ន្ធ (ឬមិនផ្លូវការ)៖** ជាទូទៅនៅគ្រប់តំបន់ទាំងអស់ គំរូក្រៅផ្លូវការពាក់ព័ន្ធនឹងសហគ្រិនម្នាក់ៗ (រស់នៅក្នុង ឬក្រៅភូមិ) ឬក្រុមហ៊ុនតូចៗជាភាគីអ្នកទិញ (ឬអ្នកម៉ៅការ)។ ជាធម្មតាពួកគេធ្វើកិច្ចសន្យាផលិតកម្មក្រៅផ្លូវការសាមញ្ញជាមួយកសិករម្នាក់ៗតាមរដូវ ជាពិសេសសម្រាប់ដំណាំរយៈពេលខ្លីដូចជាបន្លែ និងផ្លែឈើ។ ម៉្យាងវិញទៀត កសិករភាគច្រើនលក់កសិផលដល់អន្តរការីណាដែលអាចផ្តល់តម្លៃខ្ពស់ជាងគេ។ ភាគីអ្នកទិញកម្រធ្វើកិច្ចសន្យាជាមួយសហគមន៍កសិកម្មណាស់។ ជាទូទៅ កិច្ចសន្យាមានទម្រង់ក្រៅផ្លូវការ ឬកិច្ចព្រមព្រៀងជាពាក្យសំដី។ ភាគីអ្នកទិញនៅក្នុងគំរូនេះជាធម្មតាជាអ្នកកែច្នៃ អ្នកលក់រាយ ឬអ្នកបោះដុំ។ ផលិតផលកសិផលគ្រាន់តែត្រូវការជ្រើសរើសតាមកម្រិតល្អ លេខ១ លេខ២ លេខ៣ ហើយរៀបចំតម្រៀប វេចខ្ចប់ ឬត្រូវការការកែច្នៃតិចតួចតែប៉ុណ្ណោះ ហើយធ្វើដឹកជញ្ជូន។

ផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺត្រូវផ្តោតជាចម្បងថាតើភាគីអ្នកផលិត និងភាគីអ្នកទិញស្ម័គ្រចិត្តចូលរួមចំណែកកម្រិតណាទៅលើធនធានសំខាន់ៗចំនួន ៥ដូចជាដី កំលាំងពលកម្ម ទុន បច្ចេកទេស និងទីផ្សារ។ នៅក្នុងដំណាក់កាលដំបូងនៃការចរចា ភាគីទាំងពីរជាពិសេសត្រូវចរចាគ្នាជាមុននូវការរៀបចំនិងការចូលរួមកម្រិតណា និងយ៉ាងដូចម្តេចទៅលើការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលនឹងត្រូវព្រមព្រៀងគ្នានៅដំណាក់កាលបន្ទាប់។ គំរូឧទាហរណ៍មួយចំនួននៃការចូលរួមមានដូចខាងក្រោម៖

**តារាងទី១៖ គំរូនៃការចូលរួមរបស់ភាគីអ្នកផលិតនិងភាគីអ្នកទិញ**

| ប្រភេទគំរូ | ភាគីអ្នកផលិត | ភាគីអ្នកទិញ |
|---|---|---|
| ១+៤ | ដី | កំលាំងពលកម្ម, ទុន, បច្ចេកទេស, ទីផ្សារ |
| ២+៣ | ដី, កំលាំងពលកម្ម | ទុន, បច្ចេកទេស, ទីផ្សារ |
| ៣+២ | ដី, កំលាំងពលកម្ម, ទុន | បច្ចេកទេស, ទីផ្សារ |
| ៤+១ | ដី, កំលាំងពលកម្ម, ទុន, បច្ចេកទេស | ទីផ្សារ |

*ប្រភព៖ សៀវភៅណែនាំសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា (២០១៨)*[៤]

[៤] https://kampongchhnang.maff.gov.kh/post/63fc7a0f30fda

ដោយឡែក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានណែនាំបន្ថែមទៀតនូវ គំរូកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យា[៥] ដែលបានចែងអំពី (១) លក្ខខណ្ឌទូទៅ (រួមបញ្ចូលនូវកម្មវត្ថុ និងថិរវេលានៃការអនុវត្តកិច្ចសន្យា), (២) សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគី (អ្នកផលិត និងអ្នកទិញ), និង (៣) ការអនុវត្តកិច្ចសន្យា (រួមមានពេលវេលាប្រមូលផល ទីកន្លែងដឹកជញ្ជូន និងការផ្ទុកទំនិញ ការកំណត់គុណភាពផលិតផល ការកំណត់តម្លៃ ការទូទាត់ ប្រធានសក្តិ ការបញ្ចប់កិច្ចសន្យា ការដោះស្រាយវិវាទ ការបង្កើតកិច្ចសន្យានិងភាសា)។ គំរូកិច្ចសន្យានេះត្រូវភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធចំនួន ៦ ដែលបង្ហាញអំពីបញ្ជីឈ្មោះសមាជិកនិងលទ្ធភាពផលិតរបស់ភាគីអ្នកផលិតចូលរួមអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម, សេចក្តីបរិយាយអំពីគាំទ្រធាតុចូលដោយភាគីអ្នកទិញ, ការកំណត់ចំណាត់ថ្នាក់គុណភាព, បែបបទនៃការទូទាត់ថ្លៃសម្រាប់ផលិតផល, កាលកំណត់និងទីកន្លែងប្រគល់ទទួលផលិតផល, និងការអនុវត្តនៅពេលមានប្រធានសក្តិកើតឡើង។

# ៥ ប្រភពនៃវិវាទនៅក្នុងការអនុវត្តកិច្ចសន្យាផលិតកម្មតាមកិច្ចសន្យា

វិវាទដែលកើតចេញពីការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មនៅក្នុងប្រទេសកម្ពុជា ច្រើនតែមានប្រភព ឬកត្តាបង្កវិវាទមួយចំនួនដូចខាងក្រោម៖

- **គុណភាព ឬបរិមាណនៃកសិផលដែលបានផ្តល់ឱ្យ ឬសម្រេច៖** ការមិនចុះសម្រុងគ្នាអាចកើតមានឡើងរវាងកសិករ និងភាគីអ្នកទិញទាក់ទងនឹងគុណភាព ឬបរិមាណនៃផលិតផលកសិកម្មដែលបានផ្គត់ផ្គង់ ដែលអាចនាំឱ្យមានជម្លោះលើការទូទាត់ និងការបំពេញកិច្ចសន្យា។

- **អនុលោមភាពរបស់អ្នកផលិត (កសិករ ឬសហគមន៍កសិករ) លើវិធីសាស្ត្រផលិតកម្ម៖** កសិករអាចមិនគោរពទាំងស្រុងនូវវិធីសាស្ត្រផលិតកម្ម និងស្តង់ដារដែលមានចែងក្នុងកិច្ចសន្យា ដែលអាចនាំឱ្យមានជម្លោះលើគុណភាពផលិតផល និងកាតព្វកិច្ចកិច្ចសន្យា។ ការណ៍នេះអាចបណ្តាលមកពីការមិនសូវយកចិត្តទុកដាក់ ឬមិនមានបទពិសោធន៍និងចំណេះដឹងគ្រប់គ្រាន់ ឬមិនមានទុនគ្រប់គ្រាន់ក្នុងការផលិត ឬការបន្តទម្លាប់ផលិតកម្មតាមបែបប្រពៃណីដែលនាំឱ្យមានការខ្វះខាតក្នុងបំពេញអនុលោមភាពតាមកិច្ចសន្យា។

[៥] គំរូកិច្ចសន្យាផលិតកម្មកសិកម្មនៅក្នុងសារាចរណ៍ណែនាំលេខ១៩៦ ស្តីពីពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា https://server.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/64206f8de8574f670bb7c33b6612ae69_1599466990.pdf

- **ការកើតឡើងនៃព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើកាតព្វកិច្ចរបស់គូភាគី៖** ព្រឹត្តិការណ៍ដែលមិនបានគ្រោងទុកជាមុន ដូចជាគ្រោះមហន្តរាយធម្មជាតិ ការផ្ទុះជំងឺ ឬការប្រែប្រួលទីផ្សារអាចកើតឡើង និងប៉ះពាល់ដល់សមត្ថភាពរបស់ភាគីណាមួយក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ដែលអាចបណ្តាលឱ្យមានវិវាទកើតឡើង។

- **ការមិនទទួលខុសត្រូវលើហានិភ័យគ្រោះធម្មជាតិរបស់ភាគីអ្នកទិញ៖** នៅក្នុងគម្រូកិច្ចសន្យា និងការអនុវត្តផ្ទាល់ ភាគីអ្នកផលិតដែលជាកសិករជាអ្នកទទួលខុសត្រូវទៅលើការខូចខាតនានាលើការផលិតពីគ្រោះធម្មជាតិ ដែលអាចធ្វើឱ្យអ្នកផលិតបាត់បង់ប្រាក់ចំណេញច្រើន ហើយអាចទទួលរងការពិន័យពីភាគីអ្នកទិញចំពោះគុណភាព និងបរិមាណផលិតផលដែលត្រូវការ។ ភាគីអ្នកទិញមិនត្រូវចងជាកាតព្វកិច្ចផ្លូវការណាមួយក្នុងការជួយចូលរួមចែករំលែកនូវការខូចខាតរបស់ភាគីអ្នកផលិតនៅក្នុងកិច្ចសន្យាទេ ឬបានត្រឹមតែចែងឱ្យមានការយល់យោគតាមការស្ម័គ្រចិត្តតែប៉ុណ្ណោះ។

- **ការអនុវត្តមិនមានប្រសិទ្ធភាពនៃយន្តការកំណត់តម្លៃ៖** យន្តការកំណត់តម្លៃដែលបានឯកភាព ឬអនុវត្តមិនត្រឹមត្រូវតាមកិច្ចសន្យាអាចនាំឱ្យមានការខ្វែងគំនិតគ្នាលើការកំណត់តម្លៃដើម្បីឱ្យមានយុត្តិធម៌ និងតម្លាភាព។ ជំលោះនេះអាចប៉ះពាល់ដល់ផលចំណេញ និងលទ្ធភាពនៃការឆ្លើយតបផ្សេងៗ សម្រាប់ទាំងកសិករ និងភាគីអ្នកទិញ។

- **ការលួចលក់ឱ្យឈ្មួញដទៃដើម្បីបានតម្លៃខ្ពស់ជាង៖** ជាទូទៅនៅក្នុងបរិបទនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងប្រទេសកម្ពុជា ភាគីអ្នកផលិតត្រូវបានរកឃើញថាមានការលួចលក់ផលិតផលរបស់ខ្លួនទៅឱ្យឈ្មួញផ្សេងទៀត ដោយសារតែត្រូវបានគេផ្តល់តម្លៃខ្ពស់ជាង ដែលជាយុទ្ធសាស្ត្រទីផ្សាររបស់ឈ្មួញកណ្តាលក្នុងការប្រកួតប្រជែងគ្នា។ ការណ៍នេះបានធ្វើឱ្យមានភាពមិនអនុលោមភាពតាមកិច្ចសន្យារបស់កសិករចំពោះភាគីអ្នកទិញ ដែលនាំមានការទំនាស់កើតឡើងលើបញ្ហាបរិមាណបញ្ជារទិញផលិតផលមិនគ្រប់គ្រាន់។

- **មូលដ្ឋានគ្មានតម្លាភាពសម្រាប់ការបញ្ចប់កិច្ចសន្យា៖** ភាពមិនច្បាស់លាស់ ឬកង្វះភាពច្បាស់លាស់នៅក្នុងលក្ខខណ្ឌនៃកិច្ចសន្យាទាក់ទងនឹងលក្ខខណ្ឌ និងដំណើរការសម្រាប់ការបញ្ចប់កិច្ចព្រមព្រៀងអាចនាំឱ្យមានជម្លោះនៅពេលដែលភាគីម្ខាងស្វែងរកការចាកចេញពី ឬចង់បញ្ចប់កិច្ចសន្យា។

លើសពីនេះ កាតព្វកិច្ចជាច្រើនរបស់គូភាគី ជាពិសេសកាតព្វកិច្ចរបស់អ្នកផលិត ទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ និងការខិតខំឱ្យអស់លទ្ធភាព ដែលនេះជាស្តង់ដាមួយដែលអាចបង្កជាការបកស្រាយផ្ទុយគ្នា ច្រើនជាងករណីដែលទាមទារឱ្យសម្រេចបាននូវលទ្ធផលកំណត់ក្នុងគោលដៅនៃកិច្ចសន្យា។ ដូច្នេះ នៅពេលធ្វើការចរចា និងតាក់តែងកិច្ចសន្យានេះ គូភាគីត្រូវបានផ្តល់យោបល់ច្បាស់លាស់ឱ្យសម្លឹងមើលអំពីវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ ដែលគូភាគីមិនអាចមានលទ្ធភាពដោះស្រាយដោយខ្លួនឯងបាន ហើយត្រូវការឱ្យមានអន្តរាគមន៍របស់បុគ្គលទីបី (តតីយជន) នៅក្នុងកំឡុងពេលណាមួយនោះ។

កិច្ចសន្យាផលិតកម្មកសិកម្មអាចរងឥទ្ធិពលយ៉ាងខ្លាំងពីកត្តាខាងក្រៅជាច្រើន ដែលអាចធ្វើឱ្យគូភាគីទាំងពីរមិនគោរពតាមកាតព្វកិច្ចនៃកិច្ចសន្យា។ ព្រឹត្តិការណ៍ខាងក្រៅដែលអាចប៉ះពាល់ដល់កិច្ចសន្យា ជាពិសេសបាតុភូតធម្មជាតិ ដូចជា ខ្យល់ព្យុះ ទឹកជំនន់ ភាពរាំងស្ងួត និងកត្តាសត្វល្អិតចង្រៃបំផ្លាញដំណាំជាដើម។ លើសពីនេះ ការប្រែប្រួលនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យកសិកម្មក៏អាចប៉ះពាល់ដល់ការអនុវត្តកិច្ចសន្យានេះផងដែរ។ លទ្ធភាពអាចកើតឡើងនៃកត្តា ឬព្រឹត្តិការណ៍ខាងក្រៅទាំងនេះដែលប៉ះពាល់ដល់កិច្ចសន្យាផលិតកម្មកសិកម្ម មានកម្រិតខ្ពស់ព្រោះកិច្ចសន្យាកសិកម្មត្រូវបានកំណត់ចិរវេលាមធ្យម ឬចិរវេលាវែង ហើយដែលគូភាគីត្រូវមានកាតព្វកិច្ចត្រូវបំពេញជាចាំបាច់នៅពេលខាងមុខ។ នៅក្នុងករណីនេះ កាតព្វកិច្ចរបស់គូភាគីមានអន្តរទំនាក់ទំនងគ្នាទៅវិញទៅមក ហើយការសម្រេចបាននូវបន្ទុកទទួលខុសត្រូវរបស់ភាគីមួយអាចអាស្រ័យលើការបំពេញកាតព្វកិច្ចរបស់ភាគីម្ខាង ឬផ្សេងទៀត។ ស្ថិតក្នុងទិដ្ឋភាពបែបនេះ យន្តការដែលមានប្រសិទ្ធភាពសម្រាប់កាត់បន្ថយ និងដោះស្រាយវិវាទ មានសារៈសំខាន់យ៉ាងខ្លាំងណាស់សម្រាប់ការពារសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនីមួយៗ និងធានាបាននូវភាពជោគជ័យនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ប្រភពនៃជម្លោះទាំងនេះបង្ហាញពីលក្ខណៈស្មុគស្មាញ និងពហុភាគីនៃទំនាក់ទំនងនៅក្នុងការអនុវត្តកសិកម្មតាមកិច្ចសន្យាក្នុងប្រទេសកម្ពុជា។ ការដោះស្រាយបញ្ហាទាំងនេះតាមរយៈការរៀបចំកិច្ចសន្យាដែលមានលក្ខណៈល្អប្រសើរឡើងនិងធានាបាននូវសមធម៌, យន្តការពង្រឹងការអនុវត្តឱ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាព, និងការធានាឱ្យបាននូវតម្លាភាពនិងការប្រាស្រ័យទាក់ទងឱ្យកាន់តែច្រើនរវាងភាគីពាក់ព័ន្ធទាំងអស់អាចជួយកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃជម្លោះ និងលើកកម្ពស់ប្រព័ន្ធកសិកម្មតាមកិច្ចសន្យាប្រកបដោយនិរន្តរភាព និងសមធម៌។

# ៦ គ្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការដោះស្រាយវិវាទ អំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

ការដោះស្រាយទំនាស់ មានន័យថាជា ការដោះស្រាយវិវាទ ឬការដោះស្រាយការខ្វែងគំនិតគ្នា។ ដើម្បីឱ្យមានលក្ខណៈប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន ការដោះស្រាយវិវាទពាក់ព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា គួរតែត្រូវបានកំណត់អត្ថន័យ ឬ និងផ្តល់ការយល់ឃើញសម្រាប់អនុវត្ត ក្នុងលក្ខណៈ ទូលាយដែលអាចក្រសោបបញ្ចូលនូវវិវាទផ្ទាល់ និងវិវាទពាក់ព័ន្ធ ព្រមទាំងមូលហេតុផ្អែកលើតួអង្គដែលនាំឱ្យមានការខកខាន ការបំពាន ឬ ការមិនបំពេញកាតព្វកិច្ចនៃកិច្ចព្រមព្រៀងសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យា ទោះជាផ្អែកលើកិច្ចសន្យាតាមការកំណត់របស់ទីផ្សារ កិច្ចសន្យាដែលកំណត់អំពីការគ្រប់គ្រងលើផលិតកម្ម កិច្ចសន្យាដែលកំណត់អំពីការផ្តល់ធនធាន ឬកិច្ចសន្យាពហុគោលបំណងសម្រាប់ផលិតកម្មកសិកម្ម ការផ្គត់ផ្គង់ ការទំនាក់ទំងទីផ្សារ ឬនិងការផ្តល់ហិរញ្ញវត្ថុក្នុងលក្ខណៈជាដៃគូក៏ដោយ។

**ក្រមរដ្ឋប្បវេណី** បានចែងលម្អិតអំពីកិច្ចសន្យា និងសុចរិតភាពនានាដែលចាំបាច់ត្រូវអនុវត្តដើម្បីធានាឱ្យបាននូវផលប្រយោជន៍នៃភាគី។ គន្ថីទី៥ អំពីកាតព្វកិច្ច មាន ៩ជំពូកសំខាន់ៗដែលក្នុងនោះមានចែងយ៉ាងជាក់លាក់អំពីការបង្ហាញឆន្ទៈនិងកិច្ចសន្យា (ជំពូកទី២), ការអនុវត្តកិច្ចសន្យា (ជំពូកទី៣), ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា (ជំពូកទី៤), ការទទួលបន្ទុកហានិភ័យ (ជំពូកទី៥), អានុភាពនៃសិទ្ធិលើបំណុលចំពោះតតិយជន (ជំពូកទី៦), ការរលត់កាតព្វកិច្ច (ជំពូកទី៧), អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល (ជំពូកទី៨), និងអនុប្បទានសិទ្ធិលើបំណុល ការទទួលកាតព្វកិច្ច (ជំពូកទី៩)។[៦]

អនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ឆ្នាំ២០១១បានចែងថា នៅពេលមានវិវាទទាក់ទងនឹងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម គូភាគីវិវាទត្រូវស្វែងរកការសម្រុះសម្រួលគ្នា ផ្អែកតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាជាមុនសិន ហើយបន្ទាប់មក ប្រសិនបើមិនអាចដោះស្រាយបានតាមនីតិវិធីសម្រុះសម្រួលដែលគូភាគីបានព្រមព្រៀងគ្នា ឬនិងតាមរយៈស្ថាប័នជំនាញមានសមត្ថកិច្ច ភាគីវិវាទអាច (មិនមែនត្រូវតែ) ស្វែងរកអន្តរាគមន៍ ឬការសម្រុះសម្រួលទំនាស់កិច្ចសន្យា ឬការខ្វែងគំនិតគ្នា ដោយយន្តការសម្របសម្រួលជាពិសេសពេលដែលបញ្ហា ឬទំនាស់នោះតម្រូវឱ្យមានការដោះស្រាយអន្តរស្ថាប័ន។

ច្បាប់ស្តីពីសហគមន៍កសិកម្ម ឆ្នាំ២០១៣ បានកំណត់ពីនីតិវិធីនៃការដោះស្រាយទំនាស់ ឬវិវាទពាក់ព័ន្ធជាមួយសមាជិកសហគមន៍កសិកម្ម សហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម ឬនិងភាគីតតិយជនឯកជន។ មាត្រា១០៣ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម ចែងថា៖ វិវាទទាំងឡាយណាដែលកើតចេញពីសមាជិកនិងសមាជិកសហគមន៍កសិកម្ម រវាងសមាជិកនិងសហគមន៍កសិកម្មត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្មសាមីនោះ។ ក្នុងករណីដែលមហាសន្និបាតមិនអាចដោះស្រាយវិវាទបាន ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាលក្រុង ស្រុក ខណ្ឌសាមីមិនអាចដោះស្រាយវិវាទបាន មន្ទីរកសិកម្មរាជធានីខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។ ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។ មាត្រា១០៤ ចែងថាវិវាទទាំងឡាយណាដែលកើតរវាងសហគមន៍កសិកម្ម និងសហគមន៍កសិកម្ម មន្ទីរកសិកម្មរាជធានីខេត្ត និងគណៈអភិបាលរាជធានីខេត្តសាមីត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។ ក្នុងករណីវិវាទនៅតែមិនអាចដោះស្រាយបាន នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។ មាត្រា១០៥ លើកឡើងបន្ថែមថាវិវាទទាំងឡាយដែលកើតចេញពីសហគមន៍កសិកម្ម ជាសមាជិក និងសហភាពសហគមន៍កសិកម្ម ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ត្រូវដោះស្រាយដោយមហាសន្និបាតប្រចាំឆ្នាំ ឬមហាសន្និបាតវិសាមញ្ញនៃសហភាពសហគមន៍កសិកម្មសាមី ឬសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា។

[៦] Commentary_2010_CivilCode_Part_2.pdf - Google Drive

ក្នុងករណីដែលមហាសន្និបាតនៅតែមិនអាចដោះស្រាយ គណៈអភិបាលរាជធានី ខេត្តសាមី និងនាយក ដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយ។ ដោយឡែក មាត្រា១០៦ កំណត់ថាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអន្តរាគមន៍សម្របសម្រួលដោះស្រាយរាល់វិវាទទាំងឡាយដែលមិនអាចបញ្ចប់បានរវាង ក) សមាជិក និងសមាជិកសហគមន៍កសិកម្ម, ខ) សមាជិក និងសហគមន៍កសិកម្ម, គ) សហគមន៍កសិកម្ម និងសហគមន៍កសិកម្ម, ឃ) សហគមន៍កសិកម្ម ជាមួយសហភាពសហគមន៍កសិកម្ម, និង ង) សហគមន៍កសិកម្ម ឬសហភាពសហគមន៍កសិកម្ម ជាមួយសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ឬអង្គភាពក្រៅណាមួយជាមួយសហគមន៍កសិកម្ម។ ក្នុងករណីដែលភាគីពាក់ព័ន្ធដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិធ្វើបណ្តឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ឬតុលាការក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសេចក្តីសម្រេច។ ដោយឡែក មាត្រា៩៣ បានចែងពីភារកិច្ចរបស់សហភាពសហគមន៍កសិកម្ម ដែលមួយក្នុងចំណោមនោះគឺជួយសម្រុះសម្រួលវិវាទដែលអាចកើតមានរវាងសមាជិក និងសមាជិករបស់ខ្លួន ឬវិវាទជាមួយតតិយជន។

# ៧ ការអនុវត្តការដោះស្រាយវិវាទកិច្ចសន្យា នៃផលិតកម្មតាមកិច្ចសន្យា

នៅក្នុងគំរូនៃកិច្ចសន្យាផលិតកម្មកសិកម្មដែលណែនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រការ១១ បានចែងថាក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយគ្នាជាមុន។[៧] ក្នុងករណីដែលមិនអាចដោះស្រាយបាន នោះវិវាទនឹងត្រូវបញ្ជូនទៅគណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទរាជធានី ខេត្តដើម្បីធ្វើការដោះស្រាយបន្ត។ ករណីនៅតែមិនអាចដោះស្រាយបានទៀត វិវាទនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការអភិវឌ្ឍនិងសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា (គ.អ.ស.ផ.ក.) ដើម្បីដោះស្រាយ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការគឺជាការសម្រេចចុងក្រោយ។ ប៉ុន្តែភាគីវិវាទអាចដាក់ពាក្យបណ្តឹងបន្តទៅតុលាការក្នុងករណីដែលចាំបាច់។ ផ្អែកតាមបទពិសោធន៍នៃការអនុវត្តជាក់ស្តែងរបស់សហគមន៍កសិកម្ម និងក្រុមហ៊ុនបញ្ញាទិញ និងការស្នើឡើងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកកសិកម្មតាមកិច្ចសន្យា ការដោះស្រាយវិវាទពីការអនុវត្តកិច្ចសន្យាត្រូវអនុវត្តឡើង ដូចមានសង្ខេបក្នុងដ្យាក្រាមទី១ និងការពិពណ៌នាដូចខាងក្រោម៖

[៧] គំរូកិច្ចសន្យាផលិតកម្មកសិកម្មនៅក្នុងសារាចរណ៍ណែនាំលេខ១៩៦ ស្តីពីពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាhttps://server.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/64206f8de8574f670bb7c33b6612ae69_1599466990.pdf

## ១. ការចចារគ្នារវាងភាគីអ្នកផលិតនិងភាគីអ្នកទិញ

ជាទូទៅនៅពេលដែលមានទំនាស់កើតឡើង ភាគីទាំងពីរបានជួបចរចា និងពិភាក្សាគ្នាលើការខ្វែងគំនិតនានាដែលច្រើនតែពាក់ព័ន្ធជាមួយគុណភាព បរិមាណតម្លៃ និងកាលបរិច្ឆេទនៃផលិតកម្ម។ វិធីសាស្ត្រដោះស្រាយដំបូងនេះគឺមានប្រសិទ្ធភាព ហើយត្រូវមានអនុវត្តញឹកញាប់ជាងគេ ដោយសារភាគីទាំងពីរឈរលើកត្តាយោគយល់និងអធ្យាស្រ័យគ្នាខ្ពស់ទៅវិញទៅមក។ ការចចារនិងពិភាក្សារវាងភាគីអ្នកផលិតនិងភាគីអ្នកទិញ គឺជាគន្លងសំខាន់សម្រាប់ដោះស្រាយទំនាស់ និងរកឱ្យឃើញនូវមូលហេតុបង្កទំនាស់ និងការស្វែងយល់អំពីគ្នាឱ្យបានច្បាស់លាស់។ នៅពេលដែលមានទំនាស់កើតឡើង ការចចារនេះជាវិធីសាស្ត្រដោះស្រាយដំបូងដែលមានប្រសិទ្ធភាព។ ទាំងពីរភាគីត្រូវមានការយល់ដឹងនិងអធ្យាស្រ័យគ្នាខ្ពស់ ដើម្បីកសាងសមាឌភាព និងដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន។ កត្តាសំខាន់ៗក្នុងការចចារនិងពិភាក្សា៖

### (ក) គុណភាព



ភាគីអ្នកទិញត្រូវប្រាកដថាផលិតផលដែលបានចចារមានគុណភាពនិងលក្ខណៈយ៉ាងដូចម្តេចខ្លះ ដោយមានការបង្ហាញពីស្តង់ដារនិងនីតិវិធីត្រួតពិនិត្យគុណភាព។ ចំណែកឯភាគីអ្នកផលិតក៏ត្រូវផ្តល់នូវព័ត៌មាន និងការបញ្ជាក់ពីគុណភាពផលិតផលដែលបានព្រមព្រៀង ដើម្បីបង្កើនជំនឿទុកចិត្តនិងអនុលោមភាព។

### (ខ) បរិមាណ



ការពិភាក្សាអំពីបរិមាណនៃផលិតផលត្រូវធានាថាផលិតផលដែលបានបញ្ជាទិញ គឺមានបរិមាណត្រឹមត្រូវតាមតម្រូវការដូចមានចែងក្នុងកិច្ចសន្យា។ ចំពោះបរិមាណដែលខ្វះ ឬលើស ភាគីទាំងពីរត្រូវចចារគ្នាតាមការយោគយល់ ដោយផ្អែកលើសមត្ថភាពរបស់ភាគីអ្នកផលិត និងអ្នកទិញ។

### (គ) តម្លៃ



តម្លៃជាបញ្ហាដែលតែងតែធ្វើអោយមានការចចារខ្លាំង។ ភាគីទាំងពីរត្រូវតែពិភាក្សាអំពីតម្លៃដែលអាចទទួលយកបាន និងសម្រួលតម្លៃឱ្យសមស្របទៅនឹងគុណភាព និងបរិមាណផលិតផល។ បន្ថែមពីលើនេះ តម្លៃត្រូវតែជាតម្លៃដែលបានព្រមព្រៀងគ្នាកាលពីដើមគ្រា។ ក្នុងករណីដែលមានការប្រែប្រួលតម្លៃនៅពេលប្រមូលទិញ ភាគីអ្នកផលិតនិងអ្នកទិញត្រូវ ផ្តល់នូវជម្រើសណាមួយដើម្បីកែលម្អតម្លៃ ឬបន្ថែមលក្ខណៈពិសេសដើម្បីកាត់បន្ថយការតវ៉ា។

### (ឃ) កាលបរិច្ឆេទផលិតកម្ម



កាលបរិច្ឆេទផ្តល់ផលិតផលដល់ភាគីអ្នកទិញ និងសម្រាប់ទឹកប្រាក់ដែលត្រូវទូទាត់ គឺជាកត្តាសំខាន់សម្រាប់ ភាគីទាំងពីរ ដើម្បីធានាថាផលិតផលអាចធ្វើការផ្តល់ជូនបាននិងថវិកាត្រូវបានតាមរយៈកាលបរិច្ឆេទដែលបានកំណត់។

ជាអនុសាសន៍សម្រាប់វិធីសាស្ត្រដោះស្រាយ, ភាគីទាំងពីរត្រូវមានការសន្ទនាគ្នាដោយសេរី មានការទទួលខុសត្រូវខ្ពស់ និងប្រកបដោយភាពស្មោះត្រង់។ ភាគីទាំងពីរត្រូវមានការប្តេជ្ញាចិត្តក្នុងការស្វែងរកដំណោះស្រាយដែលទទួលយកបានពីគ្នា ដើម្បីធានាថាការសម្រេចចិត្តគឺសមស្រប។ បន្ថែមពីលើនេះ ភាគីទាំងពីរត្រូវចែករំលែកនិងផ្តល់ឱ្យគ្នាទៅវិញទៅមក ច្បាស់លាស់ និងពេញលេញនូវព័ត៌មានពាក់ព័ន្ធនឹងទំនាស់ដែលកំពុងកើតមានឡើង ដើម្បីបានជាបច្ច័យក្នុងការសម្របសម្រួល និងផ្សះផ្សារគ្នា។ ជារួម ការចចារនិងពិភាក្សា គឺជាឧបករណ៍ដែលអាចបង្កើនទំនាក់ទំនង និងការសហការនៅក្នុងអាជីវកម្ម ហើយជួយដោះស្រាយបញ្ហា និងទំនាស់ដែលអាចកើតឡើងបានយ៉ាងមានប្រសិទ្ធភាពផងដែរ។

## ២. ការសម្រុះសម្រួលពីអាជ្ញាធរមូលដ្ឋាន

នៅពេលដែលភាគីទាំងពីរមិនអាចឯកភាពគ្នាទៅលើដំណោះស្រាយនិងការចរចានៅដំណាក់កាលដំបូង ពួកគេអាចស្នើសុំការជួយសម្រុះសម្រួលពីអាជ្ញាធរមូលដ្ឋានដែលជាទូទៅជាមេឃុំ-ចៅសង្កាត់ដែលជាអ្នកបានដឹងលឺអំពីកិច្ចសន្យាផលិតកម្ម។ ភាគីទីបីអាច ផ្តល់នូវការយល់ដឹងល្អអំពីបញ្ហា និងតម្រូវការរបស់ភាគីទាំងពីរ ហើយអាចជួយបង្កើតនូវបរិយាកាសពិភាក្សាដែលធានាបាននូវសន្តិសុខ និងសុវត្ថិភាព ទាំងរូបវ័ន្តនិងផ្លូវចិត្ត។ ភាគីទាំងពីរត្រូវផ្តល់ដល់ភាគីទីបីនូវព័ត៌មានពីទំនាស់ដែលបានកើតឡើង និងជំហរដែលបានប្រកាន់យក ព្រមទាំងការលើកឡើងនូវអត្ថប្រយោជន៍និងហានិភ័យដែលអាចកើតមានសម្រាប់ភាគីទាំងពីរ។ អាជ្ញាធរមូលដ្ឋានអាចជួយបង្ហាញចំណុចដែលភាគីទាំងពីរមិនបានយល់ត្រឹមត្រូវតាមកិច្ចសន្យា និងអាចជួយផ្តល់នូវចំណុចគន្លឹះមួយចំនួនសម្រាប់ពិចារណាដែលអាចជួយក្នុងការសម្រុះសម្រួលទំនាស់។ ម្យ៉ាងទៀត ភាគីទីបីអាចជួយការបង្កើតជំហរថ្មីដែលអាចទទួលយកបានពីគ្នា ឬអាចជួយចែករំលែក ឬផ្តល់នូវមេរៀន ឬឧទាហរណ៍នានាពីករណីជោគជ័យដែលធ្លាប់កើតមានកន្លងមក។

## ៣. ការសម្រុះសម្រួលពីគណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទ

ការសម្រុះសម្រួលពីគណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទ នៃគណៈកម្មាធិការអភិវឌ្ឍនិងសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា (គ.អ.ស.ផ.ក.)៖ នៅពេលដែលការដោះស្រាយវិវាទនៅដំណាក់កាលមុនៗមិនទទួលបានជោគជ័យ ភាគីវិវាទអាចស្នើសុំការសម្រុះសម្រួលបន្ថែមទៀតពីគណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម) ដើម្បីពិភាក្សានិងបញ្ចប់វិវាទ។ គណៈកម្មការអាចធ្វើការត្រួតពិនិត្យការអនុវត្តន៍នៃកិច្ចសន្យា និងចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រដោះស្រាយ។ នៅពេលដែលមានទំនាស់កើតឡើង ភាគីវិវាទអាចស្នើសុំការសម្រុះសម្រួលពីគណៈកម្មការ តាមរយៈលិខិតផ្លូវការទៅមន្ទីរកសិកម្ម ដែលនឹងត្រូវបញ្ជូនបន្តទៅក្រសួងកសិកម្ម និង គ.អ.ស.ផ.ក.។ នៅពេលទទួលបានសំណើ គ.អ.ស.ផ.ក. នឹងបង្កើតគណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទតាមរាជធានី-ខេត្តដែលសំណើនោះបញ្ជូនមក។ គណៈកម្មការនេះមានតួនាទីសម្របសម្រួល ផ្សះផ្សា និងដោះស្រាយវិវាទជាក់លាក់ក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទដែលកើតចេញពីការអនុវត្តកិច្ចសន្យាផលិតកម្មត្រូវផ្អែកតាមកម្មវត្ថុនៃសេចក្តីស្នើសុំ និងឬពាក្យបណ្តឹងរបស់ភាគីវិវាទ។ ភាគីនៃកិច្ចសន្យាផលិតកម្មកសិកម្មមានសិទ្ធិទទួលយកការសម្របសម្រួលនិងដោះស្រាយវិវាទតាមវិធានណាមួយដូចជា (១) ការចចារ (២) សន្ទានកម្ម និង (៣) ការផ្សះផ្សា។

គណៈកម្មការត្រូវអញ្ជើញភាគីនៃកិច្ចសន្យាផលិតកម្មកសិកម្មដើម្បីផ្តល់ព័ត៌មាន ឯកសារពាក់ព័ន្ធ ឬ ភស្តុតាងនានាដើម្បីជាមូលដ្ឋានសម្រាប់ការផ្សះផ្សាវិវាទ។ គណៈកម្មការនេះអាចបដិសេធសេចក្តីស្នើសុំសម្របសម្រួលនិងដោះស្រាយវិវាទរបស់ភាគីវិវាទ ក្នុងករណីភាគីស្នើសុំមិនបានបង្ហាញខ្លួនតាមការអញ្ជើញ។ យោងតាមពាក្យបណ្តឹងរបស់ភាគីវិវាទ គណៈកម្មការនឹងចុះស្រាវជ្រាវ ធ្វើអង្កេត ប្រមូលភស្តុតាង ឬសាកសួរព័ត៌មានបន្ថែមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងត្រូវធ្វើកំណត់ហេតុទុកជាសក្ខីឯកសារសម្រាប់ដោះស្រាយវិវាទ។

គណៈកម្មការអាចរៀបចំការប្រជុំជាមួយភាគីទាំងពីរ ដើម្បីពិភាក្សាពីបញ្ហាដែលកើតឡើង។ ក្នុងការប្រជុំ អ្នកដែលមានសមត្ថភាពអាចផ្តល់នូវមតិយោបល់និងអនុសាសន៍ផ្សេងៗដើម្បីដោះស្រាយទំនាស់។ គណៈកម្មការអាចជួយកំណត់ស្តង់ដារ និងលក្ខខណ្ឌដែលត្រូវគោរពក្នុងការដោះស្រាយទំនាស់រវាងភាគីទាំងពីរ។ នីតិវិធីនេះអាចជួយកសាងការយល់ដឹងល្អពីតម្រូវការនិងបញ្ហាប្រឈមនានាដែលភាគីទាំងពីរមាន។ គណៈកម្មការនឹងជួយសម្រុះសម្រួលដោយផ្តល់នូវការវាយតម្លៃស្ថានភាពទំនាស់ និងកំណត់យុទ្ធសាស្ត្រដើម្បីដោះស្រាយ តាមរយៈការពិភាក្សាជាមួយភាគីទាំងពីរ ក្នុងការស្វែងយល់ពីបញ្ហា និងស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទាំងអស់គ្នា។ ក្រសួងកសិកម្មអាចត្រួតពិនិត្យលើការអនុវត្តនូវលទ្ធផលនៃការសម្រុះសម្រួលបញ្ចប់ទំនាស់។

ក្នុងករណីវិវាទនៃការអនុវត្តផលិតកម្មតាមកិច្ចសន្យាមិនអាចសម្របសម្រួល និងដោះស្រាយបាន គណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទនឹងបញ្ជូនសំណុំរឿងករណីវិវាទនេះទៅ គ.អ.ស.ផ.ក. ដើម្បីដោះស្រាយបន្ត។ ក្នុងករណីនៅតែមិនអាចបញ្ចប់វិវាទបាននៅក្នុងសមត្ថកិច្ចរបស់ គ.អ.ស.ផ.ក. ភាគីវិវាទអាចដាក់ពាក្យបណ្តឹងទៅ **តុលាការ** ដើម្បីដោះស្រាយតាមច្បាប់ជាធរមាន ឬអាចសាកល្បងនីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់ **អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** (អ.ដ.ក.)។

## ៤. ការសម្រុះសម្រួលពីអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.)

នេះជាដំណាក់កាលចុងក្រោយមុនពេលដែលវិវាទត្រូវអនុវត្តតាមនីតិវិធីតុលាការ។ នេះជាដំណើរការដែលមានគោលបំណងដើម្បីជួយភាគីវិវាទក្នុងការសម្រុះសម្រួល និងដោះស្រាយបញ្ហាដោយគ្មានការចូលរួមពីតុលាការ។ ភាគីវិវាទអាចដាក់ពាក្យស្នើសុំការអន្តរាគមន៍ពីអាជ្ញាធរជាតិ ដោយបញ្ជាក់លម្អិតពីបញ្ហាដែលកើតឡើង។ ការដាក់ពាក្យនេះត្រូវធ្វើឡើងនៅអគ្គលេខាធិការដ្ឋាន អ.ដ.ក. ដើម្បីមានការត្រួតពិនិត្យ និងអនុម័តមុនពេលសំណុំរឿងត្រូវបានយកមកដោះស្រាយ។ នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានរៀបចំឡើងតាមការណែនាំដូចមាននៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ឧបសម្ព័ន្ធទី១ សង្ខេបនូវដំណើរការ នីតិវិធី និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងករណីដែលការដោះស្រាយតាមយន្តការ អ.ដ.ក. មិនបានជោគជ័យ ភាគីវិវាទមានសិទ្ធិបន្តសំណុំរឿងទៅកាន់ **សាលាដំបូងរាជធានី ខេត្ត** ហើយអនុវត្តតាមនីតិវិធីតុលាការដែលមានស្រាប់។

ស្របជាមួយគ្នានេះផងដែរ **គ.អ.ស.ផ.ក.** ត្រូវរៀបចំឱ្យមាននូវគតិយុត្ត ឬគោលការណ៍ណែនាំលម្អិតអំពីនីតិវិធីនិងក្រមក្នុងការដោះស្រាយវិវាទលើកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីបង្កើតឱ្យមាននូវមូលដ្ឋាន និងស្តង់ដារគ្រឹះក្នុងការជួយដល់ភាគីពាក់ព័ន្ធ ជាពិសេសមន្ត្រីមានសមត្ថកិច្ចក្នុងការរៀបចំផែនការ ចាត់ចែង និងអនុវត្តការងារដោះស្រាយវិវាទឱ្យធានាបាននូវតម្លាភាព យុត្តិធម៌ និងភាតរភាព។ បន្ថែមពីលើនេះ **គ.អ.ស.ផ.ក.** គួរតែដាក់បញ្ចូលនូវសមាសភាពតំណាងពី អ.ដ.ក. ដើម្បីឱ្យការងារដោះស្រាយវិវាទអនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់។ សម្រាប់គោលបំណងជាយុទ្ធសាស្ត្រ ការបណ្តុះបណ្តាលបំពាក់បំប៉ន និងកសាងសមត្ថភាពជាប្រចាំដល់គណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទ, **គ.អ.ស.ផ.ក.** និងភាគីពាក់ព័ន្ធអំពីវិវាទ និងនីតិវិធីដោះស្រាយវិវាទ (ជាពិសេសក្រៅប្រព័ន្ធតុលាការ) ចាំបាច់ត្រូវតែធ្វើឡើងដើម្បីជំរុញនូវប្រសិទ្ធការងារឱ្យកាន់តែប្រសើរឡើងលើការងារដោះស្រាយ ការទប់ស្កាត់ និងកាត់បន្ថយវិវាទនៅក្នុងបរិបទនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងប្រទេសកម្ពុជា។ ម៉្យាងទៀត **គ.អ.ស.ផ.ក.** និងភាគីពាក់ព័ន្ធត្រូវដាក់ចេញនូវផែនការរៀបចំនិងផ្សព្វផ្សាយនូវគតិយុត្តអំពីផលិតកម្មតាមកិច្ចសន្យា និង/ឬគោលការណ៍ណែនាំអំពីការទប់ស្កាត់ បញ្ចៀស កាត់បន្ថយ និងយន្តការដោះស្រាយវិវាទនៅក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ទៅដល់កសិករ សហគមន៍កសិកម្ម ឃុំ-សង្កាត់ មន្ទីរពាក់ព័ន្ធ និងក្រុមហ៊ុនឯកជន (ភាគីអ្នកទិញ) ទាំងអស់ ។

ដ្យាក្រាមទី១៖ ការអនុវត្តការដោះស្រាយវិវាទផលិតកម្មកសិកម្មតាមកិច្ចសន្យា



# ៨ គោលការណ៍គន្លឹះក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

គោលការណ៍ខាងក្រោមនេះ ត្រូវបានដកស្រង់ចេញពីគោលការណ៍ណែនាំសម្រាប់ការប្រតិបត្តិកសិកម្មតាមកិច្ចសន្យាដែលត្រូវបានបោះពុម្ពនិងណែនាំ ដោយអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១២។[៨] គោលការណ៍គន្លឹះទាំងនេះនឹងជួយរួមចំណែកកាត់បន្ថយនូវទំនាស់ ឬវិវាទដែលកើតចេញពីការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ទី១



**គោលបំណងរួមគ្នា៖** កសិករ និងអ្នកទិញគួរមានគោលបំណងរួមនៅពេលរៀបចំនូវកិច្ចសន្យា។ ការរៀបចំគួរតែផ្អែកលើគោលការណ៍ដែលថា កិច្ចសន្យានឹងការពារភាគីទាំងពីរពីហានិភ័យដែលអាចកើតមានក្នុងអំឡុងពេលបំពេញភារកិច្ច និងជួយសម្រួលដល់ការអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា។ គោលបំណងគឺថាកិច្ចសន្យាគួរតែជំរុញផលិតកម្មកសិកម្មនិងធានាសុវត្ថិភាពទីផ្សារ ដែលការណ៍នេះនឹងជួយឱ្យ កសិករបង្កើនប្រាក់ចំណូល ហើយអ្នកទិញទទួលនូវផលចំណេញត្រឡប់មកវិញផងដែរ។ ការវិនិយោគបែបនេះគឺការវិនិយោគ ឈ្នះ-ឈ្នះ។

ទី២



**អនុលោមភាពតាមគតិយុត្ត៖** ការប្រកាន់ខ្ជាប់នូវអនុលោមភាពតាមក្របខ័ណ្ឌច្បាប់និងគតិយុត្តនានាដើម្បីគ្រប់គ្រងកិច្ចកិច្ចសន្យា, កសិករ និងអ្នកទិញចាំបាច់ត្រូវយល់ព្រមដើម្បីរៀបចំនិងអនុវត្តកិច្ចសន្យា។ ដើម្បីឱ្យមានសុពលភាព កិច្ចសន្យាត្រូវតែអនុលោមតាមតម្រូវការចំនួនជាចាំបាច់ដូចជា៖ ភាគីត្រូវតែមានស្ថានភាព និងសមត្ថភាពស្របច្បាប់ដើម្បីចុះកិច្ចសន្យា និងត្រូវមានការឯកភាពយល់ព្រមតាមរយៈការជូនដំណឹងនិងផ្តល់ព័ត៌មានគ្រប់គ្រាន់។ ក្នុងករណីដែលក្រុម ឬសហគមន៍ចូលរួមក្នុងកិច្ចសន្យា វាជាការចាំបាច់ណាស់ដែលត្រូវតែបញ្ជាក់ឱ្យច្បាស់ថាទំនួលខុសនានាត្រូវស្ថិតនៅជាមួយសមាជិកម្នាក់ៗ ឬជាមួយក្រុម ឬសហគមន៍នោះ។ នេះនឹងអាស្រ័យលើប្រភេទនៃក្រុម ឬសហគមន៍ និងច្បាប់ជាតិជាធរមាន។ កិច្ចសន្យាគួរតែមានការសរសេរអំពីការបញ្ចប់ដោយការទទួលយកនូវការផ្តល់ជូនពីភាគីម្ខាង (ឧ. អ្នកទិញ) ទៅឱ្យដល់ភាគីម្ខាងទៀត (ឧ. កសិករ)។ បន្ថែមពីលើនេះ កិច្ចសន្យាគួរបញ្ជាក់ឱ្យច្បាស់អំពីទំនួលខុសត្រូវផ្សេងៗរបស់ភាគីទាំងឡាយ។ លើសពីនេះទៀត, កិច្ចសន្យាត្រូវតែផ្អែកលើ «ផលិតផល» (ឧ. ផលិតផល ឬសេវាកម្មដែលផលិត ឬបង្កើតឡើងដែលជាកម្មវត្ថុនៃកិច្ចសន្យារវាងកសិករ និងអ្នកទិញ) ដូចជាការលក់ផលិតផលដំណាំដែលត្រូវបានកំណត់ ដោយកសិករ និងការទូទាត់ថវិកាដោយអ្នកទិញ។ ចំណុចចុងក្រោយគឺថាកិច្ចសន្យាត្រូវតែផ្អែកលើការពិពណ៌នាលំអិតអំពីកាតព្វកិច្ច និងទំនួលខុសត្រូវរបស់អ្នកទិញ និងកសិករ ដែលរួមបញ្ចូលទាំងតម្លៃនិងវិធីសាស្ត្រនៃការទូទាត់។ "ផលិតផល" និង "គុណភាពនៃផលិតផល" នៃកិច្ចសន្យាត្រូវតែស្របច្បាប់ ពោលគឺមិនខុសច្បាប់ អសីលធម៌ ឬផ្ទុយពីគោលនយោបាយសាធារណៈឡើយ ។

[៨] សម្រាប់ព័ត៌មានបន្ថែមសូមពិនិត្យតំណភ្ជាប់ https://www.fao.org/4/i2858e/i2858e.pdf

**ទី៣**

**ភាពច្បាស់លាស់នៃឯកសារ៖** ជាការប្រសើរណាស់ដែលកិច្ចសន្យាគួរតែបញ្ជាក់ជាលាយលក្ខណ៍អក្សរ ដើម្បីចងក្រងជាឯកសារនូវលក្ខខណ្ឌដែលភាគីបានយល់ព្រម និងសិទ្ធិទទួលបានការអនុវត្តកាតព្វកិច្ចរបស់ភាគីទាំងឡាយ ដូចដែលបានរៀបរាប់នៅក្នុងលក្ខខណ្ឌរបស់កិច្ចសន្យា។ កិច្ចសន្យាជាលាយលក្ខណ៍អក្សរត្រូវរៀបចំឡើងដើម្បីផ្តល់ភាពច្បាស់លាស់អំពីគោលការណ៍ណែនាំ និងតម្រូវការអំពីការយល់ព្រមលើគុណភាពនៃផលិតផល, លក្ខខណ្ឌទាក់ទងនឹងតម្លៃ, ការទូទាត់និងការចែកចាយផលិតផល និងការការពារជម្លោះដែលកើតឡើងដោយសារការយល់ច្រឡំនានា។ ក្នុងករណីកដែលភាគីទាំងពីរឯកភាពគ្នាដោយពាក្យសំដី កិច្ចព្រមព្រៀងនេះគួរតែមានវត្តមានរបស់សាក្សីម្នាក់ ឬច្រើនរូបដែលមិនមានអត្ថប្រយោជន៍លើសេដ្ឋកិច្ចនៃទំនាក់ទំនងរវាងកសិករនិងអ្នកទិញឡើយ។

**ទី៤**

**ភាពច្បាស់លាស់នៃកិច្ចសន្យា៖** កិច្ចសន្យាចាំបាច់ត្រូវបានសរសេរនៅក្នុងភាសាច្បាស់លាស់ និងស៊ីសង្វាក់គ្នា ដោយប្រើពុម្ពអក្សរ និងពាក្យដែលអាចងាយយល់បាន សម្រាប់ភាគីទាំងពីរ ជាពិសេសកសិករដោយសារកម្រិតអប់រំ និងពិសោធន៍នៅមានកម្រិត។ ភាពច្របូកច្របល់និងការយល់ច្រឡំអាចកើតឡើងយ៉ាងងាយស្រួល ប្រសិនបើលក្ខខណ្ឌនៃកិច្ចសន្យាមិនត្រូវបានយល់ និងពន្យល់ឱ្យបានច្បាស់លាស់។ ដើម្បីឧត្តមប្រយោជន៍ កិច្ចសន្យាត្រូវតែរៀបចំឡើងនៅក្នុងភាសាដែលភាគីទាំងពីរអាចយល់បានល្អបំផុត។ ក្នុងករណីដែលកសិករជាអនក្ខរជន អត្ថបទនៃកិច្ចសន្យាត្រូវតែបានអានឱ្យខ្លាំងនិងលឺៗដោយភាគីទីបី។

**ទី៥**

**ការយកចិត្តទុកដាក់ និងការពិនិត្យឡើងវិញ៖** អ្នកទិញគួរតែផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យដល់កសិករអាស្រ័យលើករណីនីមួយៗ ដើម្បីពិនិត្យសេចក្តីព្រាងកិច្ចសន្យា និងស្វែងរកដំបូន្មានច្បាប់នានា មុនការចុះហត្ថលេខា។ កិច្ចសន្យាគួរតែរៀបចំនិងមានសេចក្តីសន្និដ្ឋាននិងបញ្ចប់ឱ្យបានល្អជាមុនអំពីការរំពឹងទុកនានា មុនពេលការចាប់ផ្តើមនៃការអនុវត្តវដ្តវកសិកម្ម ហើយកសិករមិនគួរត្រូវបានបង្ខំមុនឡើយ ឱ្យយល់ព្រមទៅលើកិច្ចសន្យាដោយមិនបានទទួលយកដំបូន្មានចាំបាច់ណាមួយ។ អ្នកទិញគួរតែផ្តល់សិទ្ធិដល់កសិករអាចស្នើលុបចោលកិច្ចសន្យាក្នុងរយៈពេលដែលបានកំណត់។ នៅពេលដែលកិច្ចសន្យាត្រូវបានរៀបចំនិងចុះហត្ថលេខារួចរាល់ អ្នកទិញគួរតែផ្តល់ច្បាប់ចម្លងកិច្ចសន្យាមួយច្បាប់ដល់កសិករ។

**ទី៦**

**ការផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន៖** កសិករ និងអ្នកទិញគួរតែធ្វើការបង្ហាញនិងផ្សព្វផ្សាយឱ្យឃើញនិងដឹងលឺពេញលេញនូវព័ត៌មានចាំបាច់ទាំងអស់សម្រាប់ការសន្និដ្ឋាននៃកិច្ចសន្យា និងលើកកម្ពស់តម្លាភាពនៅក្នុងការចរចារទាំងអស់របស់ភាគីទាំងឡាយ។ កិច្ចសន្យាគួរបង្ហាញយ៉ាងច្បាស់អំពីបរិមាណផលិតផលដែលត្រូវផ្គត់ផ្គង់ដោយកសិករក្នុងរយៈពេលមួយ, ស្តង់ដារគុណភាពដែលត្រូវការ, និងមធ្យោបាយនៃការវាយតម្លៃទៅលើផលិតផលនិងស្តង់ដារទាំងនោះនៅពេលការដឹកជញ្ជូនមកដល់។ លក្ខខណ្ឌផ្សេងទៀតដែលអាចត្រូវបានកំណត់នៅក្នុងកិច្ចសន្យា,ប្រសិនបើត្រូវបានបង្កើតឡើងដោយអ្នកទិញ, អាចមានដូចជាពេលវេលាដែលកសិករត្រូវដឹកជញ្ជូនឱ្យ ឬ ពេលវេលាដែលអ្នកទិញតែងមកប្រមូលផលិតផល ឬការកំណត់នូវការទទួលខុសត្រូវសម្រាប់ការដឹកជញ្ជូនជាដើម។ លក្ខខណ្ឌសម្រាប់ការផ្គត់ផ្គង់ធាតុចូលផលិតកម្មដល់កសិករគួរតែមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យាផងដែរ។

លក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់តម្លៃផលិតផល និងមធ្យោបាយក្នុងការផ្ទៀងផ្ទាត់ គួរតែត្រូវបានបញ្ជាក់ឱ្យបានច្បាស់។ កិច្ចសន្យាចាំបាច់ត្រូវតែបញ្ចូលនូវខ្លឹមសារអំពីរយៈពេលនៃកិច្ចសន្យា និងលក្ខខណ្ឌសម្រាប់ការបញ្ចប់កិច្ចសន្យា, ឧទាហរណ៍ដូចជាការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបញ្ចប់នៅក្នុងរយៈពេលសមរម្យណាមួយ។

**ទី៧**

**តម្លាភាពក្នុងការកំណត់តម្លៃ៖** ការកំណត់តម្លៃនិងការទូទាត់គឺជាធាតុសំខាន់នៃកិច្ចសន្យាទាំងឡាយ ហើយចំណុចទាំងនេះត្រូវការយល់ច្បាស់និងយល់ព្រមដោយកសិករ និងអ្នកទិញ។ ជាការចាំបាច់ណាស់ដែលថាភាគីទាំងឡាយត្រូវចរចាដើម្បីយល់ព្រមតម្លៃដែលភាគីទាំងអស់ពេញចិត្តគ្នាទៅវិញទៅមក ហើយភាគីទាំងសងខាងត្រូវគោរពយ៉ាងម៉ឺងម៉ាត់នូវកិច្ចសន្យានេះ។ តម្លៃនិងវិធីសាស្រ្តទូទាត់ប្រាក់គួរតែត្រូវបានកំណត់យ៉ាងប្រុងប្រយ័ត្ននៅក្នុងកិច្ចសន្យា រួមទាំងព័ត៌មានទាំងអស់ដែលចាំបាច់ ដើម្បីធានាភាពច្បាស់លាស់ក្នុងការអនុវត្តឃ្លា ឬកថាខណ្ឌនីមួយៗនៅក្នុងកិច្ចសន្យា។ ខ្លឹមសារសំខាន់មួយទៀតផងដែរ គឺការបញ្ជាក់នៅពេលណា និងកន្លែងណាដែលការទូទាត់តម្លៃដល់កសិករនឹងត្រូវបានធ្វើឡើង។ ម្យ៉ាងវិញទៀត កិច្ចសន្យាគួរតែធានាតម្លាភាពក្នុងការកំណត់តម្លៃ និងនីតិវិធីនៃការទូទាត់ ។ ខ្លឹមសារទាំងនេះគួរតែជៀសវាងនូវរូបមន្តស្មុគស្មាញ ឬការវាស់វែងទៅលើបរិមាណនិងគុណភាព ដែលធ្វើឱ្យកសិករពិបាកយល់ពេញលេញ។ បន្ថែមពីលើនេះ កិច្ចសន្យាគួរតែមានបង្ហាញឱ្យច្បាស់នូវការចោទប្រកាន់ ឬការកាត់បន្ថយណាមួយដែលអាចប៉ះពាល់ដល់ចំនួនទឹកប្រាក់សុទ្ធ (ឌុល) ដែលត្រូវបង់ឱ្យកសិករនៅក្រោមលក្ខខណ្ឌនៃកិច្ចសន្យា។ កិច្ចសន្យាក៏គួរតែផ្តល់ផងដែរនូវតម្លាភាពលើព័ត៌មានទាក់ទងនឹងការចំណាយ និងតម្លៃនៃធាតុចូល និងសេវាកម្មណាមួយ ដែលត្រូវបានផ្គត់ផ្គង់ដល់កសិករ ។ សំខាន់លើនេះទៀត កិច្ចសន្យាគួរតែអនុញ្ញាតឱ្យមានការផ្តល់សិទ្ធិក្នុងការចរចារតម្លៃឡើងវិញក្នុងករណីដែលមានព្រឹត្តិការណ៍ដោយមិនបានគ្រោងទុកជាមុន ដូចជាការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងលក្ខខណ្ឌទីផ្សារដែលនាំឱ្យមានតម្លៃប្រែប្រួលដែលអាចប៉ះពាល់ទៅលើលក្ខខណ្ឌដែលបានចុះកិច្ចសន្យាជាមួយកសិករ។

**ទី៨**

**តម្លាភាព និងយុត្តិធម៌ ក្នុងឃ្លាដែលទាក់ទងនឹងគុណភាព៖** អ្នកទិញរំពឹងថាកសិករនឹងចូលរួមក្នុងការអនុវត្តផលិតកម្ម និងនីតិវិធីនានាដែលធានាដល់ការផលិតផលិតផលដែលមានគុណភាពល្អ។ ការអនុវត្តបែបនេះរួមមានការប្រើប្រាស់បានត្រឹមត្រូវនូវធាតុចូលផលិតកម្មដែលត្រូវបានណែនាំសម្រាប់ប្រភេទនៃផលិតផលកសិកម្មដែលចាំបាច់ត្រូវលូតលាស់ ឬចិញ្ចឹមបានល្អ។ កសិករក៏ត្រូវបានគេរំពឹងថានឹងអនុវត្តការគ្រប់គ្រងបានល្អ ដែលកិច្ចការនេះអាចរួមបញ្ចូលនូវការថែទាំលក្ខខណ្ឌអនាម័យ, ការប្រើប្រាស់សម្ភារៈស្អាត និងទឹកស្អាត និងការការពារផលិតផលពីកំដៅខ្លាំងជាដើម។ ជាគំនិតល្អបំផុតនោះគឺថាការរំពឹងទុកទាំងនេះគួរតែត្រូវបានបង្ហាញជាទម្រង់នៃឃ្លាកិច្ចសន្យាច្បាស់លាស់។ ម្យ៉ាងវិញទៀត កិច្ចសន្យាក៏គួរតែបង្ហាញមិនគ្រាន់តែប្រភេទនៃដំណើរការផលិតដែលបានណែនាំដល់កសិករប៉ុណ្ណោះទេ ប៉ុន្តែក៏គួរបង្ហាញនូវការគ្រប់គ្រងក្រោយការប្រមូលផលផងដែរ ដែលអាចមានការពិពណ៌នាអំពីសម្ភារៈ ឬឧបករណ៍ដែលត្រូវប្រើ, និងបញ្ជាក់ភាគីណាដែលនឹងផ្គត់ផ្គង់នូវសម្ភារៈ ឬឧបករណ៍ទាំងនោះ ជាមួយនិងតម្លៃផងដែរ។ បន្ទាប់ពីប្រមូលផល កសិករត្រូវបានគេរំពឹងថានឹងអនុវត្តតាមជាមួយនឹងបច្ចេកទេស និងវិធីសាស្រ្តនៃការគ្រប់គ្រងក្រោយការប្រមូលផលដែលជាតម្រូវការជាក់លាក់ ដើម្បីទប់ស្កាត់ការបំផ្លាញ

ឬទម្រង់ផ្សេងទៀតនៃការបាត់បង់ ឬខូចខាតផលិតផល។ ភាគីអ្នកទិញគួរតែតឹងរ៉ឹងប្រកាន់ខ្ជាប់នូវកម្រិតគុណភាពផលិតផល ឬទំនិញដែលបានព្រមព្រៀងគ្នា និងត្រូវលើកកម្ពស់នូវមធ្យោបាយប្រកបដោយតម្លាភាព និងយុត្តិធម៌ក្នុងការវាយតម្លៃគុណភាពនៃផលិតផល ឬទំនិញដែលប្រគល់ជូន។ កសិករ និងអ្នកតំណាងរបស់ពួកគេ គួរតែមានសិទ្ធិមានវត្តមាននៅពេលនៃការដឹកជញ្ជូននិងទទួលផលិតផល ហើយក៏ត្រូវទទួលបានពេញលេញនូវការពន្យល់ក្នុងករណីណាមួយដែលមានការបដិសេធ ឬទម្លាក់ចំណាត់ថ្នាក់ផលិតផល។ ភ្លាមៗក្រោយពីពេលដឹកជញ្ជូននិងចែកចាយ កសិករគួរទទួលបានរបាយការណ៍ជាលាយលក្ខណ៍អក្សរនូវបរិមាណនិងចំណាត់ថ្នាក់ ផលិតដែលត្រូវបានទទួល សម្រាប់ផលិតផលរបស់ពួកគេ។

ទី៩

**តម្លាភាព និងយុត្តិធម៌៖** នៅក្នុងឃ្លា និងកថាខណ្ឌលក្នុងកិច្ចសន្យាគួរតែបញ្ជាក់ឱ្យច្បាស់ថាតើភាគីណានឹងទទួលខុសត្រូវសម្រាប់ផ្គត់ផ្គង់ និងប្រើប្រាស់នូវធាតុចូលកសិកម្មទាំងឡាយ។ នៅពេលដែលកិច្ចសន្យាមានគម្រោងអំពីការផ្គត់ផ្គង់ធាតុចូល (ឧ. ថ្នាំសំលាប់សត្វល្អិត ជី គ្រាប់ពូជ ប្រេងឥន្ធនៈ ធាតុចូលផ្នែកពេទ្យសត្វ ចំណី ។ល។) មុនពេលចាប់ផ្តើមរដូវកាលកសិកម្មនីមួយៗ ធាតុចូលទាំងអស់នោះគួរតែត្រូវបានកំណត់អត្តសញ្ញាណនិងបញ្ជាទិញឱ្យបានរួចរាល់ មុនពេលនៃប្រតិបត្តិការកសិកម្មដូចជាការសាបព្រួស ការស្ទូង ឬការចិញ្ចឹមសត្វ។ នៅពេលដែលកសិករត្រូវការធាតុចូលទាំងនោះសម្រាប់ការដាំដុះដំណាំក្រោមកិច្ចសន្យា អ្នកទិញអាចពិចារណាក្នុងការផ្គត់ផ្គង់ធាតុចូលទាំងនោះ ហើយកាត់កងប្រាក់ចំណាយវិញនៅពេលដែលកសិករធ្វើការដឹកជញ្ជូនផលិតផលដែលបានចុះកិច្ចសន្យាមកប្រគល់ជូន។ ប្រសិនបើធាតុចូលទាំងនោះត្រូវបានផ្គត់ផ្គង់ដោយអ្នកទិញ ធាតុចូលដែលត្រូវបានកំណត់ក្នុងកិច្ចសន្យាគួរតែបំពេញតាមតម្រូវការស្តង់ដាគុណភាពក្នុងតម្លៃនោះ ពោលគឺមិនត្រូវមានតម្លៃខ្ពស់ជាងតម្លៃពាណិជ្ជកម្មលើទីផ្សារនោះឡើយ។ ម៉្យាងទៀត ធាតុចូលទាំងនោះគួរតែត្រូវបានដឹកជញ្ជូនឱ្យបានទាន់ពេលវេលា ដើម្បីកសិករអាចប្រើប្រាស់បានទាន់ពេលវេលាសម្រាប់អត្ថប្រយោជន៍លើដំណាំរបស់ពួកគាត់។ ក្នុងករណីណាដែលអ្នកទិញទទួលខុសត្រូវក្នុងការផ្តល់ជូនកសិករនូវធាតុចូល និងការជំពាក់មុនទាំងឡាយ កសិករមិនគួរប្រើប្រាស់ធាតុចូល និងអទិភាពទាំងនេះសម្រាប់គោលបំណងផ្សេងទៀតឡើយ ក្រៅតែអំពីគោលបំណងដូចមានចែងក្នុងកិច្ចសន្យា។ កសិករក៏គួរធ្វើតាមការអនុវត្តដែលបានណែនាំ ដើម្បីបំពេញតាមលក្ខណៈជាក់លាក់ និងបង្កើនផលត្រឡប់មកវិញឱ្យបានច្រើនពីការប្រើប្រាស់ធាតុចូលដែលផ្គត់ផ្គង់ដោយអ្នកទិញ។

ទី១០

**យុត្តិធម៌ក្នុងការចែករំលែកការទទួលខុសត្រូវហានិភ័យ៖** ឧប្បត្តិហេតុបង្ខំនិងភាពបត់បែនតាមកិច្ចសន្យាកិច្ចសន្យា គួរជាចំណុចពិចារណាសម្រាប់លទ្ធភាពនៃការចរចាកិច្ចសន្យាឡើងវិញ។ រវាងកសិករ និងអ្នកទិញ ក៏គួរតែបញ្ជាក់ផងដែរអំពីបញ្ហានៃការចែករំលែកហានិភ័យផលិតកម្មនិងទីផ្សារក្នុងចំណោមភាគីទាំងពីរ។ ក្នុងករណីដែលអាចគ្រប់គ្រងបានទៅលើហានិភ័យនៃជំងឺរុក្ខជាតិ ឬសត្វដែលអាចរារាំងផលិតកម្មពីការឈានដល់កិច្ចសន្យា ការរំលែកបន្ទុកហិរញ្ញវត្ថុគួរតែត្រូវបានចែង ឬរៀបចំឡើងតាមរបៀបមួយដែលសមស្របជាមួយការទទួលខុសត្រូវរបស់ភាគីនីមួយៗ សម្រាប់ព្រឹត្តិការណ៍ ឬបញ្ហាដែលបង្កឡើង។ ឧទាហរណ៍បញ្ហាដែលកើតឡើងដោយសារការផ្គត់ផ្គង់ធាតុចូល ឬការផ្តល់ដំបូន្មាន

បច្ចេកទេសដោយអ្នកទិញមិនបានគ្រប់គ្រាន់ មិនគួរមានលទ្ធផលនៃកំហាតហិរញ្ញវត្ថុសម្រាប់កសិករទេ។ ផ្ទុយទៅវិញបញ្ហាដែលបណ្តាលមកពីការគ្រប់គ្រងមិនត្រឹមត្រូវ, ការប្រើប្រាស់មិនគ្រប់គ្រាន់នៃធាតុចូល ឬការមិនគោរពតាមជាមួយនឹងដំបូន្មានបច្ចេកទេសដែលផ្តល់ដោយអ្នកទិញ ក៏មិនតែគួរពិន័យតែអ្នកទិញនោះដែរ។ ក្នុងករណីគ្រោះមហន្តរាយធម្មជាតិ (ទាក់ទងនឹងអាកាសធាតុ មិនមែនប៉េស្ត ឬជំងឺដែលអាចគ្រប់គ្រងបាន) ឬគ្រោះមហន្តរាយដែលមនុស្សបង្កើត (សង្គ្រាម,ជម្លោះស៊ីវិល, កូដកម្ម) ដែលអាចចាត់ទុកថាជាមហាឧបទ្ទវហេតុ បណ្តាលឱ្យកសិករ ឬអ្នកទិញមិនអាចបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យា ភាគីទាំងពីរគួរតែត្រូវបានចាត់ទុកថាមិនត្រូវទទួលខុសត្រូវការមិនដំណើរការទាំងឡាយ និងនៅក្នុងកាលៈទេសៈទាំងនេះ កិច្ចសន្យាគួរតែមានចែងអំពីការផ្តល់ឱកាសសម្រាប់ការចរចាឡើងវិញ។ ការចរចាឡើងវិញគួរតែផ្អែកលើគោលការណ៍នៃការចែករំលែកស្មើគ្នានៃការចំណាយ (ការខូចខាត) ឬអត្ថប្រយោជន៍ដែលកើតចេញពីព្រឹត្តិការណ៍ដែលត្រូវបានចាត់ទុកថាជាមហាឧបទ្ទវហេតុ។ លទ្ធភាពនៃការឱ្យមានកម្មវិធីធានារ៉ាប់រង ប្រឆាំងនឹងការខូតខាចដំណាំ ឬការបាត់បង់សត្វចិញ្ចឹមក៏គួរឱ្យមានជាការវាយតម្លៃមួយសម្រាប់ជាមធ្យោបាយនៃការគ្រប់គ្រងហានិភ័យផងដែរ។

ទី១១



**ការទប់ស្កាត់ការអនុវត្តបែបអយុត្តិធម៌ក្នុងទំនាក់ទំនងអ្នកទិញ-កសិករ៖** កិច្ចសន្យាមិនគួរហាមឃាត់ ឬមិនលើកទឹកចិត្តកសិករអំពីទំនាក់ទំនងជាមួយកសិករដទៃទៀតក្នុងការប្រៀបធៀបខ្លឹមសារនៃកិច្ចសន្យា ឬដើម្បីដោះស្រាយបញ្ហា ឬក្តីកង្វល់ផ្សេងៗ។ លើសពីនេះទៅទៀត កិច្ចសន្យាក៏មិនគួរហាមឃាត់ ឬបំបាក់ទឹកចិត្តកសិករពីការពិភាក្សាអំពីកិច្ចសន្យាជាមួយដៃគូរអាជីវកម្ម ឬស្វែងរកជំនួយវិជ្ជាជីវៈផ្នែកច្បាប់ ហិរញ្ញវត្ថុ ឬការណែនាំអំពីផលិតកម្មកសិកម្មទាក់ទងនឹងលក្ខខណ្ឌ កាតព្វកិច្ច និងទំនួលខុសត្រូវនានាដែលមាននៅក្នុងកិច្ចសន្យា។ អ្នកទិញមិនគួរចូលរួមនៅក្នុងសកម្មភាពនៃការសងសឹក ឬការរើសអើងចំពោះការអនុវត្តប្រឆាំងនឹងកសិករដែលហ៊ានអនុវត្តសិទ្ធិរបស់ពួកគេប្រឆាំងនឹងពួកគេវិញទេ, ដូចជាការដាក់ពាក្យបណ្តឹងប្រឆាំងនឹងការប្រព្រឹត្តខុសច្បាប់របស់អ្នកទិញដែលយល់ឃើញដោយកសិករ។ ម្យ៉ាងវិញទៀត អ្នកទិញគួរតែមិនបំភាន់លក្ខខណ្ឌកិច្ចសន្យាដែលជាការលើកទឹកចិត្តដល់កសិករឱ្យចុះហត្ថលេខាលើកិច្ចសន្យា។ អ្នកទិញគួរតែជៀសវាងស្ថានភាពដែលអាចនាំឱ្យមានការមិនពេញចិត្តរបស់កសិករ ដូចជាការទិញដោយរើសអើង (ការយកចិត្តទុកដាក់លើការទិញមិនស្មើគ្នារវាងកសិករ), ការទូទាត់យឺតយ៉ាវ, ការផ្តល់សេវានិងដំបូន្មានបច្ចេកទេសមិនល្អដែលគ្មានប្រសិទ្ធភាព និងការដឹកជញ្ជូនដែលមិនគួរឱ្យទុកចិត្តសម្រាប់ផលិតផលកសិកម្ម។ បន្ថែមពីលើនេះ អ្នកទិញមិនគួរផ្លាស់ប្តូរកូតាផលិតកម្មដែលបានព្រមព្រៀងជាមុន ដោយលើកហេតុផលអំពីការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារក្នុងការប៉ុនប៉ងដើម្បីជៀសវាងការទិញផលិតផលតាមកិច្ចសន្យា។ លើសពីនេះទៀត អ្នកទិញមិនគួរបដិសេធការផ្តល់ផលិតផលនៅពេលកសិករបានត្រៀមរួចរាល់ដើម្បីផ្គត់ផ្គង់ដល់ពួកគេ។ ដើម្បីរក្សាការជឿទុកចិត្ត និងការគោរព អ្នកទិញត្រូវតែធានាឱ្យមានតម្លាភាពនិងភាពយុត្តិធម៌ក្នុងអំឡុងពេលនៃដំណើរការទិញលក់។

**ទី១២**

**គោរពលក្ខខណ្ឌនៃកិច្ចសន្យា៖** កសិករ និងអ្នកទិញគួរស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក។ ការជឿទុកចិត្តនិងការគោរពទៅវិញទៅមកគឺសំខាន់កត្តាសម្រាប់ភាពជោគជ័យលើការប្រតិបត្តិការកសិកម្មតាមកិច្ចសន្យា។ ដើម្បីជៀសវាងការមិនយល់ស្រប, អ្នកទិញគួរតែធានាថាកសិករទាំងអស់មានព័ត៌មានចាំបាច់ដើម្បីពួកគេអាចដាំដុះ ប្រមូលផល និងផ្គត់ផ្គង់កសិផលដែលត្រូវការ, ហើយអ្នកទិញគួរតែធានាថាពួកគេនឹងទិញកសិផលទាំងនោះរបស់កសិករតាមពេលវេលាកំណត់។ ផ្ទុយទៅវិញកសិករគួរតែផ្គត់ផ្គង់ផលិតផលបំពេញតាមស្តង់ដារគុណភាពដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យា។ កសិករគួរគោរពការប្តេជ្ញាចិត្តដែលបានយល់ព្រមនៅក្នុងកិច្ចសន្យាក្នុងការផ្គត់ផ្គង់កសិផលដោយប្រើប្រាស់ធាតុចូល និងហិរញ្ញប្បទានដែលផ្តល់ដោយអ្នកទិញផ្តាច់មុខចំពោះតែកិច្ចសន្យារបស់អ្នកទិញជាក់លាក់នោះ លើកលែងតែមានជម្រើសការរៀបចំផ្សេងទៀតត្រូវបានបញ្ជាក់នៅក្នុងកិច្ចសន្យា។ កសិករមិនគួរលក់កសិផលទាំងអស់ ឬផ្នែក ឬបរិមាណណាមួយនៃផលិតកម្មរបស់ខ្លួនទៅអ្នកទិញផ្សេងទៀត ប្រសិនបើមានគេឱ្យតម្លៃខ្ពស់ក៏ដោយ។ ដោយឡែក អ្នកទិញមិនគួរសងសឹក ឬផ្លាស់ប្តូរលក្ខខណ្ឌនៃកិច្ចសន្យានៅពេលបរិយាកាសទីផ្សារ ឬគោលនយោបាយរដ្ឋាភិបាលមានការផ្លាស់ប្តូរ។ គេណែនាំថាកសិករ ឬអ្នកតំណាងរបស់ពួកគេមានវត្តមាននៅពេលដែលកសិផលត្រូវបានប្រមូលពីកសិដ្ឋាន ឬបញ្ជូនទៅដល់កន្លែងរបស់អ្នកទិញ។ ក្នុងព្រឹត្តិការណ៍នៃការបដិសេធលើកសិផល, អ្នកទិញគួរតែជូនដំណឹងដល់កសិករអំពីហេតុផល និងផ្តល់ឱ្យពួកគេនូវឱកាសដើម្បីត្រួតពិនិត្យលើការបដិសេធ ឬអាចឱ្យមានភាគីទីបីមកត្រួតពិនិត្យបន្ថែម។

**ទី១៣**

**ការសន្ទនា និងទំនាក់ទំនងដោយបើកចំហ៖** ការសន្ទនារវាងកសិករ ឬអ្នកតំណាងរបស់ពួកគេ និងអ្នកទិញមានសារៈសំខាន់សម្រាប់ស្ថេរភាពនៃប្រតិបត្តិការកសិកម្មតាមកិច្ចសន្យា។ កង្វះទំនាក់ទំនងរវាងពួកគេអាចនាំទៅដល់ការយល់ច្រឡំនិងជម្លោះ។ ការសន្ទនារវាងភាគីទាំងឡាយគួរតែត្រូវបានលើកកម្ពស់លើនូវបញ្ហាដូចជាលក្ខខណ្ឌកិច្ចសន្យា និងតម្រូវការសម្រាប់ការដាំដុះលើដី ឬការចិញ្ចឹមសត្វ ក៏ដូចជាជួយកែតម្រូវការយល់ច្រឡំនិងដោះស្រាយលើជម្លោះផ្សេងៗ។ ម៉្យាងទៀត កសិករ និងអ្នកទិញគួរតែជួបគ្នានៅដើមរដូវនីមួយៗដើម្បីឱ្យអ្នកទិញអាចពន្យល់ពួកគេអំពីកម្មវិធីគ្រប់គ្រង បញ្ជាក់ពីភារកិច្ចរបស់ភាគីទាំងពីរដូចដែលបានកំណត់ក្នុងកិច្ចសន្យា និងជួយដោះស្រាយនូវបញ្ហាដែលកំពុងកើតមានណាមួយ។

**ទី១៤**

**យន្តការច្បាស់លាស់ដើម្បីដោះស្រាយជម្លោះ៖** កសិករ និងអ្នកទិញគួរយល់ព្រមគ្នានៅក្នុងកិច្ចសន្យាលើវត្តមាននៃភាគីទីបីអព្យាក្រឹតដើម្បីជួយពួកគេក្នុងករណីមានជម្លោះ។ នៅពេលដែលជម្លោះតាមកិច្ចសន្យាកើតឡើង ភាគីទាំងពីរត្រូវខិតខំដើម្បីដោះស្រាយក្នុងលក្ខណៈជាភាតរភាព។ ប្រសិនបើការប៉ុនប៉ងដោះស្រាយទាំងនេះបរាជ័យ ភាគីទាំងពីរគួរស្វែងរកការសម្របសម្រួល ឬការធ្វើមជ្ឈត្តកម្មឱ្យបានពេញលេញ មុនពេលបន្តនីតិវិធីនៃដំណើរការដោះស្រាយទៅដល់នីតិវិធីតុលាការ។ ប្រសិនបើអ្នកទិញគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុនមេ ក្រុមហ៊ុនមេនោះគួរតែទទួលខុសត្រូវចំពោះកសិករសម្រាប់បំណុល និងការទាមទារណាមួយដែលពាក់ព័ន្ធអ្នកទិញ។ បើកសិករនិងអ្នកទិញដែលមានទីតាំងនៅប្រទេសផ្សេងៗគ្នា កិច្ចសន្យាគួរបញ្ជាក់ថាតើច្បាប់របស់ប្រទេសណាគួរត្រូវយកមកអនុវត្តក្នុងករណីមានជម្លោះកើតឡើង។

# ៩ ក្របខ័ណ្ឌគោលការណ៍កាត់បន្ថយវិវាទ ក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាតែងនាំមកនូវវិវាទ និងការខ្វះខាតក្នុងការបំពេញកាតព្វកិច្ចរបស់ភាគីនីមួយៗ។ ដ្យាក្រាមទី២ ខាងក្រោមសង្ខេបនូវក្របខ័ណ្ឌគន្លឹះក្នុងការកាត់បន្ថយវិវាទ ដោយបង្ហាញនូវប្រភេទវិវាទ យន្តការដោះស្រាយ និងគោលការណ៍ចម្បងៗក្នុងធានាការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចបញ្ចៀសបាន ឬមិនបង្កជាវិវាទធ្ងន់ធ្ងរ។ មិនថាគម្រូផលិតកម្មកសិកម្មតាមកិច្ចសន្យាបែបណាក៏ដោយ ប្រភេទវិវាទច្រើនកើតឡើងស្រដៀងគ្នាពីបញ្ហាចម្បងៗដូចជា៖ (១) ការផ្គត់ផ្គង់ផលិតផលមិនអនុលោមតាមគុណភាពដែលបានកំណត់, (២) ផ្តល់បរិមាណផលិតផលមិនគ្រប់ចំនួន ឬលើសតម្រូវដែលបានកំណត់, (៣) មិនមានអនុលោមភាពឱ្យបានត្រឹមត្រូវតាមការណែនាំទៅលើវិធីសាស្ត្រផលិត, (៤) យន្តការតម្លៃផលិតផលមិនមានតម្លាភាព ឬច្រើនតែកេងចំណេញពីអត្ថប្រយោជន៍របស់អ្នកផលិត, (៥) មិនមានលក្ខខណ្ឌច្បាស់លាស់ក្នុងការបញ្ចប់កិច្ចសន្យា, (៦) ហានិភ័យគ្រោះធម្មជាតិលើដំណើរការផលិត, (៧) មិនមានការចែករំលែកនូវការទទួលខុសត្រូវលើហានិភ័យគ្រោះធម្មជាតិរវាងអ្នកផលិត និងអ្នកទិញ, (៨) ការលក់ផលិតផលឱ្យអ្នកដទៃដើម្បីបានតម្លៃថ្លៃជាង, និង (៩) ការមិនយកចិត្តទុកដាក់តាមការណែនាំរបស់ ភាគីអ្នកទិញ ដោយបន្តអនុវត្តទម្លាប់ផលិតតាមបែបប្រពៃណីជាដើម។ ទាំងនេះសុទ្ធតែជាកត្តាបង្កជាទំនាស់ និងការមិនស្រុះស្រួលគ្នានៅពេលដែលកាលកំណត់បរិច្ឆេទប្រមូលផលិតផលមកដល់ ឬនៅចុងគ្រានៃការ អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ដើម្បីរួមចំណែកដល់ការទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយនូវវិវាទទាំងឡាយ ក្របខណ្ឌបរិយាបន្នមួយត្រូវបង្កើតឡើងដើម្បីធានាបានថាការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវបានប្រតិបត្តិត្រឹមត្រូវនិងធានាបាននូវអត្ថប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ការធានា និងសម្រេចបាននូវគោលការណ៍ខាងក្រោមនេះនឹងនាំមកនូវបរិយាកាសអំណោយផល វិជ្ជមាន និងអត្ថប្រយោជន៍សម្រាប់ភាគីទាំងឡាយ។ ទាំងនោះរួមមាន (១) អនុលោមភាពតាមគតិយុត្តជាធរមាន, (២) ភាពច្បាស់លាស់នៃកិច្ចសន្យា ឬឯកសារពាក់ព័ន្ធ, (៣) ការចែករំលែកព័ត៌មានអំពីតម្រូវការនិងបញ្ហាប្រឈមរបស់ភាគី, (៤) តម្លាភាពក្នុងការកំណត់តម្លៃ, (៥) គោលការណ៍តម្លាភាពនិងយុត្តិធម៌, (៦) ការចែករំលែកការទទួលខុសត្រូវហានិភ័យនៃផលិតកម្ម, (៧) ការគោរពលក្ខខណ្ឌនៃកិច្ចសន្យា, និង (៨) ការសន្ទនានិងទំនាក់ទំនងដោយបើកចំហររវាងភាគី។ សូមពិនិត្យចំណុច ៨ ខាងលើសម្រាប់សេចក្តីអត្ថាធិប្បាយពន្យល់ខ្លីៗបន្ថែមទៀត។ ស្របជាមួយនេះ យន្តការដោះស្រាយវិវាទដែលមានប្រសិទ្ធភាពត្រូវបង្កើតឡើងដើម្បីផ្តល់ទំនុកចិត្ត និងដោះស្រាយវិវាទរវាងគូរភាគីក្នុងការធានាបាននូវអត្ថ

ប្រយោជន៍ពេញលេញ និងត្រឹមត្រូវ។ សូមពិនិត្យនូវសេចក្តីអត្ថាធិប្បាយនូវគោលការណ៍ និងយន្តការទាំងនេះនឹងជួយលើកកម្ពស់ប្រសិទ្ធភាព និងជំរុញនូវឧត្តមានុវត្តន៍ក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងប្រទេសកម្ពុជា។

ក្របខណ្ឌនេះក៏ត្រូវភ្ជាប់មកជាមួយនូវយន្តការដោះស្រាយវិវាទដែលអាចធានាបាននូវយុត្តិធម៌ សមធម៌ និងរក្សាបាននូវអត្ថប្រយោជន៍សម្រាប់គ្រប់ភាគីពាក់ព័ន្ធ។ ភាគីទាំងអស់ត្រូវអនុវត្តតាមយន្តការ និងនីតិវិធីដូចដែលបានលើកឡើងនៅក្នុងចំណុច ៧ ខាងលើ។

**ដ្យាក្រាមទី២៖ ក្របខ័ណ្ឌបញ្ចៀស កាត់បន្ថយ និងដោះស្រាយវិវាទ**




**ប្រភពវិវាទ**

- គុណភាព ឬបរិមាណកសិផល
- អនុលោមភាពតាមវិធីសាស្ត្រផលិត
- យន្តការតម្លៃកសិផល
- ព្រឹត្តិការណ៍ ឬបាតុភូតធម្មជាតិ
- ការលក់ផលិតផលឱ្យអ្នកដទៃ
- ការបញ្ចប់កិច្ចសន្យា

**យន្តការដោះស្រាយវិវាទ**

- ការសម្រុះសម្រួលរវាងភាគីទាំងពីរ
- ការសម្រុះសម្រួលដោយអាជ្ញាធរមូលដ្ឋាន
- ការសម្រុះសម្រួលដោយគណៈកម្មការសម្របសម្រួលនិងដោះស្រាយវិវាទ
- ការសម្រុះសម្រួលដោយ គ.អ.ស.ផ.ក.
- នីតិវិធីដោះស្រាយដោយ អ.ដ.ក.
- នីតិវិធីតុលាការ

**គោលការណ៍គន្លឹះ**

- អនុលោមភាពតាមគតិយុត្ត
- ភាពច្បាស់លាស់នៃឯកសារ ឬកិច្ចសន្យា
- ការចែករំលែកព័ត៌មានអំពីតម្រូវ និងបញ្ហាប្រឈម
- តម្លាភាពក្នុងការកំណត់តម្លៃ
- គោលការណ៍តម្លាភាព និងយុត្តិធម៌
- ការចែករំលែកការទទួលខុសត្រូវហានិភ័យនៃផលិតកម្ម
- ការគោរពលក្ខខណ្ឌនៃកិច្ចសន្យា
- ការសន្ទនានិងទំនាក់ទំនងដោយបើកចំហររវាងភាគី

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

### (ក) នីតិវិធីគោលនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទទាំងឡាយណានៅក្រៅប្រព័ន្ធតុលាការ គឺត្រូវបានចាត់ទុកថាជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយបែបនេះជាជម្រើសបន្ថែមដើម្បីឆ្លើយតបទៅនឹងការដោះស្រាយតាមនីតិវិធីតុលាការដែលមានជាទូទៅមានភាពស្មុគស្មាញ ចំណាយពេលយូរ ចំណាយថវិកាច្រើន និងមានភាពតានតឹង។ វិធីសាស្ត្រដោះស្រាយនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា និងទៅលើវិវាទមួយចំនួនដូចជាវិវាទគ្រួសារ ដីធ្លី ធនធានធម្មជាតិ ការងារ ពាណិជ្ជកម្ម និងករណីស៊ីវិលផ្សេងៗទៀត។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការអាចកើតឡើងនៅពេលដែលភាគីវិវាទយល់ព្រមចូលរួមដោះស្រាយដោយសន្តិវិធី និងភាតរភាព ហើយភាគីវិវាទនៅតែអាចប្រើប្រាស់នីតិវិធីតុលាការ ប្រសិនបើភាគីវិវាទមិនពេញចិត្តជាមួយនឹងដំណោះស្រាយដែលមាន។ សម្រាប់ប្រទេសកម្ពុជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានអនុវត្តតាមនីតិវិធីចំនួន ៤សំខាន់ដែលមានដូចជា៖

---

**១. ការចរចា**

គេប្រើប្រាស់វិធីនេះដើម្បីដោះស្រាយវិវាទតាមរយៈការសម្របសម្រួលដោយគ្មានជំនួយពីភាគីទី៣។ គេអនុវត្តវិធីនៅពេលដែលភាគីវិវាទទាំងពីរយល់ព្រមគ្នាបង្កើតជាដំណោះស្រាយតាមអ្វីដែលពួកគេចង់បាន ហើយព្យាយាមពន្យល់និងពិភាក្សាគ្នារហូតដល់ឈានទៅរកដំណោះស្រាយ ឬកិច្ចព្រមព្រៀងដែលភាគីទាំងពីរពេញចិត្ត។ សម្រាប់លក្ខខណ្ឌដែលល្អបំផុត គឺថាភាគីទាំងពីរឯកភាពគ្នាដោយការចរចាដោះស្រាយវិវាទជាមួយនឹងកិច្ចព្រមព្រៀងរួមមួយ។ ជាដំបូង ភាគីនីមួយៗត្រូវលើកឡើងនូវសំណើដំណោះស្រាយដែលខ្លួនចង់បាន ហើយព្យាយាមជួបពិភាក្សាគ្នារកចំណុចឬដំណោះស្រាយរួម។ បន្ទាប់ពីបានព្រមព្រៀងគ្នាហើយ ភាគីទាំងពីររៀបចំឱ្យមាននូវកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់នូវដំណោះស្រាយទាំងឡាយដែលបានឯកភាពគ្នា។

---

## ២. សន្ទានកម្ម

សន្ទានកម្មតម្រូវឱ្យមានភាគីទី៣ ឬច្រើនដែលជាទូទៅគេស្គាល់ថាជា សន្ទានការី (ដែលមានន័យថាអ្នកសម្រុះសម្រួល)។ បុគ្គលទាំងនេះជាបុគ្គលដែលអព្យាក្រឹត និងមានតួនាទីជួយភាគីវិវាទពិភាក្សានិងស្វែងរកដំណោះស្រាយដែលអាចទទួលយកបានភាគីវិវាទទាំងពីរ។ សំណុំរឿងដែលស្ថិតនៅក្នុងដំណើរការពិភាក្សានិងស្វែងរកដំណោះស្រាយត្រូវតែជាការសំងាត់ ហើយមិនអាចជាកម្មវត្ថុសម្រាប់ការប្ដឹងជំទាស់ភាគីវិវាទម្ខាងទៀតបានទេ។ ដំណើរការធ្វើសន្ទានកម្មនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងដំណើរការផ្សះផ្សាដែលគេច្រើនអនុវត្តនៅក្នុងនីតិវិធីតុលាការផងដែរ (ដែលគេច្រើនតែស្គាល់ថាជា នីតិវិធីផ្សះផ្សារបស់តុលាការ)។ សន្ទានកម្មត្រូវបានគេរៀបចំឡើងនៅពេលដែលភាគីវិវាទទាំងព្យាយាមចរចាគ្នា តែមិនមានដំណោះស្រាយរួមណាមួយដែលអាចឯកភាពគ្នាបាន។ ដើម្បីជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ នីតិវិធីសន្ទានកម្មត្រូវអនុលោមតាមដំណាក់កាលសំខាន់ៗដូចជា ១). ការផ្ដួចផ្ដើមសន្ទានកម្ម ២). ការកំណត់និងជ្រើសរើសសន្ទានការី ៣). ការផ្ដល់ព័ត៌មាននិងសក្ខីកម្មដល់សន្ទានការី ៤). ការបើកកិច្ចប្រជុំសម្រុះសម្រួល ៥). កិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ ៦). ការប្រជុំជាឯកជន និង ៧). ការបញ្ចប់សន្ទានកម្ម។

## ៣. ការផ្សះផ្សា

នីតិវិធីនេះខុសពីការធ្វើសន្ទានកម្មដែលតម្រូវឱ្យអ្នកផ្សះផ្សាជួបជាមួយភាគីវិវាទទាំងអស់ដោយឡែកៗពីគ្នា (ជាជាងការជួបគ្នារួមដូចមាននៅក្នុងសន្ទានកម្ម) ដើម្បីស្នើឱ្យមានការសម្បទានចំពោះតម្រូវការណាមួយឱ្យដល់ភាគីវិវាទម្ខាងទៀត ហើយដំណោះស្រាយដែលបានព្រមព្រៀងគ្នាជាទូទៅមិនមែនជាកាតព្វកិច្ចផ្លូវច្បាប់។ នីតិវិធីនៃការផ្សះផ្សាគឺតម្រូវឱ្យមាននូវភាគីទី៣ដូចគ្នានឹងសន្ទានកម្មដែរ ដែលបុគ្គលនោះអាចជាព្រះសង្ឃ អាចារ្យវត្ត អ្នកមានប្រជាប្រិយភាពឬអំណាចដែលទទួលការទុកចិត្តពីភាគីវិវាទ។ ការផ្សះផ្សាត្រូវធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាលដែលទទួលបានចាត់តាំងដោយរាជរដ្ឋាភិបាល ឬអង្គចៅក្រម។

## ៤. មជ្ឈតកម្ម

ភាគីវិវាទត្រូវដាក់ពាក្យបណ្ដឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ដំណាក់កាលដំបូងគឺភាគីវិវាទត្រូវជ្រើសរើសមជ្ឈតករម្នាក់ដែលភាគីទាំងពីរទុកចិត្តដើម្បីធ្វើការពិនិត្យភស្តុតាង ឯកសារ សំណុំរឿង និងធ្វើសេចក្ដីសម្រេចចិត្ត។ ចំណុចសំខាន់គឺភាគីវិវាទមានលទ្ធភាពក្នុងការកំណត់និងជ្រើសរើសមជ្ឈតករដោយខ្លួនឯង និងត្រូវបានបង្កលក្ខណៈងាយស្រួលក្នុងការចូលរួមសវនការនិងជំនួបជាផ្លូវការដែលភាគីវិវាទអាចទាញហេតុផលអំណះអំណាង និងភស្តុតាងនានាទៅតាមសំណុំសាច់រឿងដែលខ្លួនមាន។ ភាគីវិវាទចាំបាច់ត្រូវព្រមព្រៀងគ្នាជាមុនដែលត្រូវគោរពតាមសេចក្ដីសម្រេចរបស់អាជ្ញាកណ្ដាល។ មជ្ឈតករត្រូវផ្ដល់នូវសេចក្ដីសម្រេចមួយជាលាយលក្ខណ៍អក្សរនៅពេលដែលដំណើរការមជ្ឈតកម្មត្រូវបានបញ្ចប់ ហើយសេចក្ដីសម្រេចនេះនឹងក្លាយជាកាតព្វកិច្ចអនុវត្តសម្រាប់ភាគីវិវាទ។

## (ខ) យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់ អ.ដ.ក.

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣។ អ.ដ.ក. គឺជាយន្តការស្ថាប័នថ្នាក់ជាតិបំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទដែលមានស្រាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបេសកកម្មដោះស្រាយ តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ។ អ.ដ.ក. មានចក្ខុវិស័យលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ។ គោលបំណងសំខាន់ៗរបស់ អ.ដ.ក. គឺ ១). ចូលរួមកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តី ២). បង្វិតសេវាដោះស្រាយវិវាទឱ្យកាន់តែកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និង ៣). ធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌សង្គមជាតិ។ អ.ដ.ក. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន។

អ.ដ.ក. តាមរយៈអគ្គលេខាធិការដ្ឋាន ទទួលពាក្យបណ្តឹង និងសម្របសម្រួលដោះស្រាយវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀតដែលផ្អែកតាមច្បាប់ ហើយការបញ្ចប់វិវាទទាំងនោះត្រូវចំណុះឱ្យសេរីភាពនៃឆន្ទៈនៃភាគី។ អ.ដ.ក. មិនអាចសម្របសម្រួលនិងដោះស្រាយវិវាទបែបបទល្មើសព្រហ្មទណ្ឌបានឡើយ លើកលែងតែច្បាប់អនុញ្ញាត។ រូបវន្តបុគ្គល ឬនីតិបុគ្គលអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬតាមរយៈស្ថាប័នថ្នាក់ជាតិនិងក្រោមជាតិ។ ម្យ៉ាងវិញទៀត សំណុំរឿងពីសាលាជម្រះក្តីក៏អាចត្រូវបានបញ្ជូនមក អ.ដ.ក. ក្នុងករណីភាគីវិវាទណាមួយបង្ហាញឆន្ទៈឱ្យធ្វើការសម្រុះសម្រួល។

នៅពេលបច្ចុប្បន្ននេះ  មានតួអង្គជាច្រើនដែលអាចជួយសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលការក្នុងនោះរួមមានមន្ត្រីសាធារណៈ (មន្ត្រីរាជការ), មន្ត្រីរបស់ក្រសួងយុត្តិធម៌នៅតាមមណ្ឌលសេវាយុត្តិធម៌នៅថ្នាក់ស្រុក ខណ្ឌ និងក្រុង, មន្ត្រីមូលដ្ឋានតាមឃុំ-សង្កាត់ ឬមន្ត្រីដែលទទួលអាណាត្តិដោយការបោះឆ្នោតជាពិសេសមេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់, មន្ត្រីអង្គការសង្គមស៊ីវិលដែលអាចជួយសម្រុះសម្រួលវិវាទនិងផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់។ តួអង្គមួយទៀតគឺជាមេធាវីដែលអាចជួយសម្រុះសម្រួលវិវាទក្រៅប្រព័ន្ធតុលាការបានផងដែរ។

### ខ.១. នីតិវិធីដោះស្រាយ

ពាក្យបណ្តឹងស្នើសុំឱ្យ អ.ដ.ក. សម្រុះសម្រួលផ្សះផ្សាវិវាទ អាចត្រូវបានធ្វើឡើងដោយភាគីវិវាទផ្ទាល់ ឬដោយអ្នកតំណាងស្របច្បាប់របស់ភាគីវិវាទ។ ភាគីវិវាទ ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចដាក់ពាក្យ  បណ្តឹងមក អ.ដ.ក. តាមរយៈស្ថាប័នដែលមានការពាក់ព័ន្ធ ទាំងស្ថាប័នថ្នាក់ជាតិ និងស្ថាប័នថ្នាក់ក្រោមជាតិ។

អគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ត្រូវចុះបញ្ជីសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ ទៅក្នុងសៀវភៅចុះបញ្ជីសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ បន្ទាប់ពីបានពិនិត្យពីភាពត្រឹមត្រូវ និងភាពពេញលេញនៃពាក្យ    បណ្តឹង។ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. នឹងចាត់តាំងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទចំនួន ១ (មួយ) រូប ឬច្រើនរូប តាមការចាំបាច់ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចុះបញ្ជីសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ ដើម្បីទទួលបន្ទុកពិនិត្យ និងដោះស្រាយលើសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ។ ក្នុងករណីមានការព្រមព្រៀងគ្នាលើការជ្រើសរើសមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ភាគីវិវាទអាចដាក់ពាក្យស្នើសុំមក អ.ដ.ក. ដើម្បីចាត់តាំងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនោះ ដើម្បីសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ខ្លួន។ ការដាក់ពាក្យស្នើសុំនេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដាក់ពាក្យបណ្តឹងមក អ.ដ.ក.។ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. នឹងចាត់តាំងមន្ត្រីសម្រុះសម្រួលដោះស្រាយ

វិវាទតាមការស្នើសុំរបស់ភាគីវិវាទ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែមានមូលហេតុសមរម្យក្នុងការបដិសេធពាក្យស្នើសុំរបស់ភាគីវិវាទ។

ប្រធាន អ.ដ.ក. អាចចេញសេចក្តីសម្រេចបង្កើតក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទដែលដឹកនាំដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ និងមានសមាសភាពផ្សេងទៀតចូលរួម ដែលជាអ្នកជំនាញផ្នែកច្បាប់ ឬកិច្ចការសង្គម ដើម្បីសម្រុះសម្រួលផ្សះផ្សាវិវាទតាមការចាំបាច់។ សមាសភាពនៃក្រុមការងារនេះ អាចត្រូវបានផ្លាស់ប្តូរ។ ក្នុងករណីមានការសម្រេចផ្លាស់ប្តូរមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. នឹងជូនដំណឹងអំពីសេចក្តីសម្រេចផ្លាស់ប្តូរនេះ ឱ្យបានឆាប់តាមគ្រប់មធ្យោបាយដល់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលមានការពាក់ព័ន្ធ និងភាគីវិវាទ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលត្រូវបានផ្លាស់ប្តូរត្រូវប្រគល់សំណុំរឿង និងឯកសារពាក់ព័ន្ធទាំងអស់ជូនអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីការផ្លាស់ប្តូរនេះ។

## កិច្ចដំណើរការនៃការសម្រុះសម្រួលផ្សះផ្សាវិវាទ បែងចែកជា ៣ (បី) ដំណាក់កាលដូចខាងក្រោម (ដ្យាក្រាមទី២)៖

**(ទី១)**
**ដំណាក់កាលត្រូវរៀបចំមុនកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ**

**១.១. ការពិនិត្យ សិក្សា និងស្រាវជ្រាវសំណុំរឿង៖** បន្ទាប់ពីមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវបានចាត់តាំងឱ្យទទួលបន្ទុកពិនិត្យ និងដោះស្រាយលើសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវចាប់ផ្តើមពិនិត្យ សិក្សា និងស្រាវជ្រាវលើសំណុំរឿង និងឯកសារពាក់ព័ន្ធដែល ភាគីវិវាទបានដាក់ជូន អ.ដ.ក.។ ក្នុងករណីចាំបាច់ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចធ្វើការប្រមូលនូវព័ត៌មានបន្ថែមតាមរយៈការសាកសួរភាគីវិវាទនីមួយៗ ឬបុគ្គលពាក់ព័ន្ធ ដើម្បីឱ្យផ្តល់ព័ត៌មាន ឬឯកសារបន្ថែមអំពីអង្គហេតុចំណុចវិវាទ ការទាមទារ ឬសំណូមពរ សម្រាប់ជាមូលដ្ឋានក្នុងការចាប់ផ្តើមការសម្រុះ សម្រួលផ្សះផ្សាវិវាទ។

**១.២. ការជូនដំណឹងអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការសម្រុះសម្រួលផ្សះផ្សាវិវាទ៖** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនឹងកោះអញ្ជើញភាគីវិវាទ ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀត ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទ ទីកន្លែង និងសមាសភាពចូលរួមកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ។ ការកោះអញ្ជើញនេះ នឹងត្រូវធ្វើឡើងឱ្យបានយ៉ាងតិច ៥ (ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ លើកលែងតែមានករណីបន្ទាន់ចាំបាច់ ឬមានការស្នើសុំរបស់ភាគី។ ក្នុងករណីភាគីវិវាទណាមួយ មិនបានចូលរួមក្នុងកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទតាមការកោះអញ្ជើញ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នឹងធ្វើការកោះអញ្ជើញភាគីវិវាទ ដោយកំណត់កាលបរិច្ឆេទជាថ្មី។ ក្នុងករណីដែលភាគីវិវាទណាមួយមិនចូលរួមក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទចំនួន ២ (ពីរ) លើកជាប់ៗគ្នា ដោយគ្មានមូលហេតុសមរម្យ ឬភាគីវិវាទបង្ហាញយ៉ាងច្បាស់នូវឆន្ទៈមិនចូលរួមក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវរៀបចំជារបាយការណ៍ស្តីពីការបិទបញ្ចប់សំណុំរឿង ដាក់ជូនអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ដើម្បីពិនិត្យ និងសម្រេច។ ក្នុងករណីដែលសំណុំរឿងត្រូវបានសម្រេចបិទបញ្ចប់ អគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ត្រូវជូនដំណឹងទៅភាគីវិវាទទាំងអស់អំពីការសម្រេចបិទបញ្ចប់នេះ ឬជូនដំណឹងទៅតុលាការចំពោះសំណុំរឿងដែលបញ្ជូនមកពីតុលាការ ឬទៅស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

**១.៣. ការរៀបចំទីកន្លែងសម្រាប់កិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ៖** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នឹងកំណត់អំពីទីកន្លែងដែលសមស្របសម្រាប់កិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងមូលដ្ឋាន ដើម្បីស្នើសុំទីកន្លែងសាធារណៈណាមួយ សម្រាប់រៀបចំកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ។ ទីកន្លែងសម្រាប់រៀបចំកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ ត្រូវធ្វើនៅទីតាំងណាមួយ ដែលអាចធានាបាននូវការសម្ងាត់ ឬឯកជនភាពសម្រាប់នៃកិច្ចសន្ទនា និងមានសុវត្ថិភាពសម្រាប់កិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ រួមទាំងត្រូវគិតគូរដល់តម្រូវការជាមូលដ្ឋានរបស់ភាគីវិវាទដែលមានពិការភាព។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវស្នើសុំកិច្ចអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងមូលដ្ឋាន ក្នុងករណីតិនិត្យឃើញថាអាចមានបាតុភាព ឬហេតុការណ៍ណាមួយកើតឡើងនៅទីកន្លែងសម្រុះសម្រួលផ្សះផ្សាវិវាទ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ សន្តិសុខ និងរបៀបរៀបរយនៃកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ។

**(ទី២)
ដំណាក់កាល
សម្រុះសម្រួល
ផ្សះផ្សាវិវាទ**

**២.១. ការថ្លែងបើកកិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ៖** នៅពេលចាប់ផ្តើមកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវថ្លែងបើកកិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ ដោយត្រូវធ្វើការណែនាំ ឬបញ្ជាក់នូវចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ការណែនាំខ្លួន និងតួនាទីរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ
- ការបញ្ជាក់ទៅភាគីវិវាទអំពីការស្ម័គ្រចិត្តសម្រុះសម្រួលផ្សះផ្សាវិវាទ ក្នុងក្របខ័ណ្ឌ អ.ដ.ក.
- ការពន្យល់ភាគីវិវាទអំពីកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ និងផលវិបាកដែលកើតចេញពីកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ
- ការពន្យល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីវិវាទ ឬអ្នកតំណាងរបស់ភាគីវិវាទ ឬអ្នកចូលរួមផ្សេងទៀតនៅក្នុងដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ
- ការណែនាំអំពីការគោរពបទបញ្ជាផ្ទៃក្នុង ឬគោលការណ៍សំខាន់ៗ នៃកិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ
- ការណែនាំអំពីកិច្ចការផ្សេងទៀតតាមការចាំបាច់។

**២.២. ការថ្លែងការណ៍របស់ភាគីវិវាទ៖** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវផ្តល់ឱ្យភាគីវិវាទ ឬអ្នកតំណាងរបស់ភាគីវិវាទនីមួយៗ នូវសិទ្ធិស្មើៗគ្នា ដើម្បីធ្វើសេចក្តីថ្លែងការណ៍ម្តងម្នាក់អំពីអង្គហេតុចំណុចវិវាទ ការអះអាង ការទាមទារ និង/ឬការស្នើនូវដំណោះស្រាយវិវាទរបស់ខ្លួន។

**២.៣. ការកំណត់អង្គហេតុ ចំណុចវិវាទ ការទាមទារ និងការស្នើនូវដំណោះស្រាយវិវាទ៖** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនឹងស្តាប់ភាគីវិវាទដោយសកម្ម និងធ្វើការកត់ត្រាដោយយកចិត្តទុកដាក់នូវអ្វីដែលភាគីវិវាទបានធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងអង្គហេតុ ចំណុចវិវាទ ការអះអាង ការទាមទារ និងការស្នើនូវដំណោះស្រាយវិវាទ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនឹងធ្វើការសំយោគនូវព័ត៌មានសំខាន់ៗ ដែលបានលើកឡើង ហើយអាននូវការសំយោគ និងបញ្ជាក់អំពីការយល់ព្រមពីភាគីវិវាទ។

**២.៤. ការសម្របសម្រួលឱ្យភាគីវិវាទស្វែងយល់ពីគ្នា និងការបំផុសជម្រើសនៃដំណោះស្រាយ៖** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពជួយសម្របសម្រួលឱ្យភាគីវិវាទអាចស្វែងយល់ពីទស្សនៈ និងជំហររបស់គ្នាទៅវិញទៅមក ដើម្បីស្វែងរកដំណោះស្រាយវិវាទ។ ក្នុងករណីដែលភាគីវិវាទមិនអាចឈានដល់ដំណោះស្រាយវិវាទណាមួយ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចបំផុសជំម្រើសនៃដំណោះស្រាយសមស្របនានា ព្រមទាំងត្រូវផ្តល់ពេលវេលាសមរម្យឱ្យភាគីវិវាទធ្វើការពិចារណាលើដំណោះស្រាយដែលភាគីវិវាទយល់ថាសមស្រប និងមានផលប្រយោជន៍។ ក្នុងករណីចាំបាច់ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចផ្អាកកិច្ចប្រជុំ និងធ្វើការកោះប្រជុំជាថ្មីម្តងទៀត ប្រសិនបើភាគីវិវាទត្រូវការពេលវេលាបន្ថែម ដើម្បីពិចារណាលើដំណោះស្រាយ ឬពិគ្រោះយោបល់ផ្នែកច្បាប់ជាមួយអ្នកជំនាញបន្ថែម។

**២.៥. ការប្រជុំដាច់ដោយឡែក៖** នៅគ្រប់ពេលនៃកិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ ក្នុងករណីដែលមានការស្នើសុំពីភាគីវិវាទ ឬស្ថិតក្នុងស្ថានភាពតានតឹង និងមិនអាចគ្រប់គ្រងបាន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចស្នើឱ្យមានការប្រជុំដាច់ដោយឡែកជាមួយភាគីវិវាទនីមួយៗ ដើម្បីស្តាប់យោបល់របស់ភាគីវិវាទ ពិភាក្សា ឬផ្តល់យោបល់ឱ្យភាគីវិវាទ ក្នុងគោលបំណងអាចឈានទៅរកដំណោះស្រាយមួយ ដែលភាគីវិវាទអាចទទួលយកបាន។ ការប្រជុំដាច់ដោយឡែក នឹងត្រូវធ្វើឡើងដោយធានាបាននូវឥទ្ធាភាព និងចៀសវាងនូវស្ថានភាពណាមួយដែលអាចស្តែងឱ្យឃើញនូវភាពលំអៀងរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។

**២.៦. ការវាយតម្លៃ និងចរចារកលទ្ធផលចុងក្រោយ៖** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវធ្វើការសំយោគឡើងវិញដោយធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រុះសម្រួលផ្សះផ្សាវិវាទ និងជម្រើសនៃដំណោះស្រាយនានា ដែលអាចឱ្យភាគីវិវាទធ្វើការពិបារណានិងចរចារកលទ្ធផលចុងក្រោយមុនឈានទៅដល់ការធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។

**២.៧. ការរៀបចំកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ៖** ក្នុងករណីភាគីវិវាទព្រមព្រៀងបញ្ចប់វិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនឹងចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ស្របតាមមាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងករណីភាគីវិវាទព្រមព្រៀងបញ្ចប់វិវាទតែលើចំណុចវិវាទមួយចំនួន និងមិនព្រមព្រៀងបញ្ចប់ចំណុចវិវាទមួយបំនួនផ្សេងទៀត មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នឹងចេញកំណត់ហេតុព្រមព្រៀងវិវាទ តែទៅលើចំណុចវិវាទដែលភាគីវិវាទបានព្រមព្រៀងគ្នាតែប៉ុណ្ណោះ។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវអានខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ នៅចំពោះមុខភាគីវិវាទ។ ក្រោយពីភាគីវិវាទបានយល់ច្បាស់ និងទទួលស្គាល់ថាខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទពិតជាត្រឹមត្រូវស្របតាមឆន្ទៈរបស់ខ្លួន ភាគីវិវាទត្រូវចុះហត្ថលេខា និង/ឬផ្តិតស្នាមម្រាមដៃ នៅផ្នែកខាងក្រោមនៃទំព័រនីមួយៗ ព្រមទាំងចុះហត្ថលេខា និង/ឬផ្តិតស្នាមម្រាមដៃ នៅទំព័រចុងក្រោយនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ នៅចំពោះមុខមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។ បន្ទាប់មក មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវចុះហត្ថលេខានៅផ្នែកខាងក្រោមនៃទំព័រនីមួយៗ រួចត្រូវចុះហត្ថលេខា និងប្រថាប់ត្រារបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នៅទំព័រចុងក្រោយនៃ

កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទខាងលើនេះ ត្រូវធ្វើឡើងជាភាសាខ្មែរតែមួយច្បាប់ដើម និងត្រូវតម្កល់ទុកនៅអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក.។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវចេញសេចក្តីចម្លងយថាភូតនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទសម្រាប់រក្សាទុកផ្ទាល់ខ្លួនចំនួន ១ (មួយ ) ច្បាប់ និងផ្តល់ជូនភាគីវិវាទនីមួយៗចំនួន ១ (មួយ) ច្បាប់។

**២.៨. របាយការណ៍កិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ៖** នៅរៀងរាល់កិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នឹងរៀបចំនូវរបាយការណ៍កិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទនៅពេលបញ្ចប់កិច្ចប្រជុំនីមួយៗ បើទោះបីជាកិច្ចប្រជុំនោះបានសម្រេច ឬមិនសម្រេចបាននូវការព្រមព្រៀងណាមួយក៏ដោយ។

## (ទី៣) ដំណាក់កាលក្រោយកិច្ចសម្រុះសម្រួលផ្សះផ្សាវិវាទ

**៣.១. សិទ្ធិប្តឹងតវ៉ារបស់ភាគីវិវាទ៖** ភាគីវិវាទមានសិទ្ធិប្តឹងតវ៉ាទៅ អ.ដ.ក. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ក្នុងករណីកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទធ្វើឡើងដោយមិនត្រឹមត្រូវស្របតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ក្នុងករណីមិនមានបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃខាងលើ ឬបណ្តឹងតវ៉ាត្រូវបានសម្រេចបដិសេធដោយ អ.ដ.ក. កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវចាត់ទុកថាធ្វើឡើងត្រឹមត្រូវស្របតាមស្មារតី និងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

**៣.២. អានុភាពនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ៖** កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលធ្វើឡើងត្រឹមត្រូវ ស្របតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវមានតម្លៃគតិយុត្តដូចលិខិតយថាភូត និងត្រូវទុកជាបន្ទាល់ដែលតុលាការត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ឬមានភស្តុតាងដែលបង្ហាញអំពីការក្លែងបន្លំ ឬវិការៈដទៃទៀតនៅក្នុងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះមានអានុភាពអនុវត្តដូចគ្នាទៅនឹងសាលក្រមស្ថាពររបស់តុលាការ និងត្រូវចាត់ទុកជាលិខិតអនុវត្តដូចមានចែងក្នុងមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីនេះ ភាគីវិវាទមានកាតព្វកិច្ចត្រូវអនុវត្តទៅតាមខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ ។

**៣.៣. ការស្នើសុំ និងការផ្តល់រូបមន្តអនុវត្ត៖** ក្នុងករណីភាគីវិវាទណាមួយ មិនអនុវត្តដោយស្ម័គ្រចិត្តតាមខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ឬក្នុងករណីចាំបាច់ដទៃទៀត ភាគីវិវាទអាចស្នើតាមរយៈអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ទៅមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬ អ.ដ.ក. ដែលបានចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ឱ្យផ្តល់រូបមន្តអនុវត្តចំពោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ ដើម្បីធ្វើការអនុវត្តដោយបង្ខំតាមខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ស្របតាមនីតិវិធីច្បាប់ជាធរមាន។ បន្ទាប់ពីទទួលបានពាក្យស្នើសុំឱ្យផ្តល់រូបមន្តអនុវត្ត អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. នឹងចាត់ចែងឱ្យមានការចុះបញ្ជីពាក្យសុំនោះនៅក្នុងសៀវភៅចុះបញ្ជីការអនុវត្តដោយបង្ខំ និងត្រូវបញ្ជូនពាក្យស្នើសុំនោះ និងឯកសារពាក់ព័ន្ធទៅមន្ត្រី

សម្រុះសម្រួលដោះស្រាយវិវាទ ឬ អ.ដ.ក. ដើម្បីផ្តល់រូបមន្តអនុវត្តតាមការស្នើសុំរបស់ភាគីវិវាទ។ បន្ទាប់ពីបានផ្តល់រូបមន្តអនុវត្តចំពោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬ អ.ដ.ក. ត្រូវផ្តល់ព័ត៌មានមកអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ដើម្បីចុះនិទ្ទេសអំពីការផ្តល់រូបមន្តអនុវត្តនៅក្នុងសៀវភៅចុះបញ្ជីការអនុវត្តដោយបង្ខំ។ អគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ត្រូវជូនដំណឹងភ្លាមទៅភាគីវិវាទដែលស្នើសុំ ដើម្បីមកទទួលរូបមន្តអនុវត្ត។

**៣.៤. កាតព្វកិច្ចផ្តល់របាយការណ៍លទ្ធផលនៃការដោះស្រាយវិវាទ៖** បន្ទាប់ពីបញ្ចប់ការសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការដោះស្រាយវិវាទដាក់ជូន អ.ដ.ក. ដោយត្រូវមានបញ្ជាក់ព័ត៌មានជាអាទិ៍ដូចខាងក្រោម៖

- អង្គហេតុសង្ខេប និងចំណុចវិវាទ
- រយៈពេលសរុបនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដោយរាប់គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានសំណុំរឿងពីអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. រហូតដល់កាលបរិច្ឆេទបិទបញ្ចប់ការសម្រុះ សម្រួលផ្សះផ្សាវិវាទ
- លទ្ធផលដែលទទួលបានបន្ទាប់ពីកិច្ច ចូដំណើរការសម្រុះ សម្រួលផ្សះផ្សាវិវាទ។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវផ្តល់របាយការណ៍ខាងលើជូនអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការបិទបញ្ចប់ការសម្រុះសម្រួលផ្សះផ្សាវិវាទ និងត្រូវភ្ជាប់នូវឯកសារមួយចំនួនដូចខាងក្រោម៖

- ច្បាប់ដើមនៃរបាយការណ៍កិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទទាំងអស់
- ច្បាប់ដើមនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ក្នុងករណីភាគីវិវាទព្រមព្រៀងបញ្ចប់វិវាទ
- ឯកសារផ្សេងទៀតដែលទទួលបានពីភាគីវិវាទ ឬភាគីពាក់ព័ន្ធក្នុងអំឡុងពេលនៃការសម្រុះសម្រួលផ្សះផ្សាវិវាទ។

**៣.៥. ការរក្សាទុកកំណត់ត្រា ឯកសារ និងទិន្នន័យផ្សេងៗ៖** របាយការណ៍លទ្ធផលនៃការដោះស្រាយវិវាទ ច្បាប់ដើមនៃរបាយការណ៍កិច្ចប្រជុំសម្រុះសម្រួលផ្សះផ្សាវិវាទ ច្បាប់ដើមនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ និងរាល់សំណុំឯកសារពាក់ព័ន្ធនឹងសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ ត្រូវរក្សាទុកឱ្យបានត្រឹមត្រូវនៅអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ក្នុងរយៈពេលយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការធ្វើឯកសារទាំងនោះ និងត្រូវរក្សាទុកក្នុងប្រព័ន្ធឌីជីថលឱ្យបានត្រឹមត្រូវ។

## ខ.២. ការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ អ.ដ.ក.

**១. ការចាត់តាំងសមាសភាពនៃ អ.ដ.ក. ដើម្បីសម្រុះសម្រួលផ្សះផ្សាវិវាទ៖** ក្នុងករណីចាំបាច់ និងផ្អែកតាមការស្នើសុំរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ដ.ក. ប្រធាន អ.ដ.ក. អាចចេញសេចក្តីសម្រេចចាត់តាំងសមាសភាពនៃ អ.ដ.ក. ១ (មួយ) រូប ឬច្រើនរូប ដើម្បីពិនិត្យ និងដោះស្រាយលើសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទ និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ១ (មួយ) រូប ឬច្រើនរូប ជាជំនួយការ។ ក្នុងករណីនេះ សមាសភាពនៃ អ.ដ.ក. ដែលត្រូវបានចាត់តាំង ត្រូវបានប្រគល់សិទ្ធិអំណាចដូចគ្នានឹងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ស្របតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**២. កិច្ចដំណើរការនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ អ.ដ.ក.៖** កិច្ចដំណើរការនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដោយ អ.ដ.ក. ត្រូវអនុវត្តដូចគ្នាទៅនឹងកិច្ចដំណើរការនៃការសម្រុះសម្រួលផ្សះផ្សាវិវាទដែលធ្វើឡើងដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដូចមានកំណត់ក្នុងជំពូកទី៤ នៃសេចក្តីសម្រេចនេះ[៩]។ ក្នុងករណីនេះ សមាសភាពនៃ អ.ដ.ក. ដែលត្រូវបានចាត់តាំងដើម្បីពិនិត្យនិងដោះស្រាយលើសំណុំរឿងសម្រុះសម្រួលផ្សះផ្សាវិវាទត្រូវអនុវត្តតាមសេចក្តីសម្រេចស្តីពីក្រមសីលធម៌ និងក្រមប្រតិបត្តិរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អ.ដ.ក. និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធជាធរមាន។

ការសម្របសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ អ.ដ.ក. ត្រូវធ្វើឡើងដោយមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបានការចាត់តាំងពី អ.ដ.ក. ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទដែលទទួលបានការចាត់តាំងពី អ.ដ.ក. ឬដោយ អ.ក.ដ.។ នៅក្នុងការពិនិត្យ និងសម្រុះសម្រួលដោះស្រាយវិវាទ អ.ដ.ក. ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ដ.ក. ឬមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចកោះអញ្ជើញភាគីវិវាទ សាក្សី ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត ណែនាំឱ្យភាគីវិវាទបញ្ជាក់ពីការទាមទារ ឬផ្តល់ព័ត៌មានបន្ថែមលើការទាមទារ ឬស្រាវជ្រាវព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងវិវាទ ដោយយោងតាមការចាំបាច់ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។ ភាគីវិវាទអាចត្រូវបានតំណាងដោយអ្នកតំណាងដោយអាណត្តិ ឬអមដោយមេធាវី ឬអ្នកប្រឹក្សាយោបល់របស់ខ្លួនតាមការចាំបាច់។

ក្នុងករណីភាគីវិវាទព្រមព្រៀងសះជាបញ្ចប់វិវាទនឹងគ្នា មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬ អ.ដ.ក. ដែលបានទទួលចាត់ការករណីនេះត្រូវចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ ក្នុងករណីដែលកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទធ្វើឡើងដោយមិនត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ និងបទប្បញ្ញត្តិច្បាប់ជាធរមាន ភាគីវិវាទមានសិទ្ធិប្តឹងតវ៉ាទៅ អ.ដ.ក. ក្នុងរយៈពេល ៣០ថ្ងៃគិតពីថ្ងៃធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ ក្នុងករណីមិនមានបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ថ្ងៃខាងលើ ឬបណ្តឹងតវ៉ាត្រូវបានសម្រេចបដិសេធដោយ អ.ដ.ក. កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទត្រូវចាត់ទុកថាធ្វើឡើងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលត្រូវធ្វើឡើងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ មានតម្លៃគតិយុត្តដូចលិខិតយថាភូត និងត្រូវទុកជាបន្ទាល់ដែលតុលាការត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ឬមានភស្តុតាងដែលបង្ហាញអំពីការក្លែងបន្លំ ឬវិការៈដទៃទៀតនៅក្នុងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនោះ។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ មានអនុភាពអនុវត្តដូចគ្នានឹងសាលក្រមស្ថាពររបស់តុលាការ និងត្រូវចាត់ទុកជាលិខិតអនុវត្តដូចមានចែងក្នុងចំណុច ឈ នៃកថាខណ្ឌទី២ នៃមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ការស្នើសុំអនុវត្តដោយបង្ខំនូវកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវធ្វើឡើងស្របតាមនីតិវិធីច្បាប់ជាធរមាន។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទ ឬ អ.ដ.ក. ដែលចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវផ្តល់នូវរូបមន្តអនុវត្តចំពោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ តាមការស្នើសុំ។ អ.ដ.ក. នឹងត្រូវចាត់នីតិវិធីចាំបាច់នានាដើម្បីធានាដល់ការអនុវត្តកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទដែលត្រូវធ្វើឡើងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ។ ប្រសិនបើខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទនេះ ផ្ទុយនឹងបទប្បញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទំលាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ភាគីដែលមានការពាក់ព័ន្ធអាចប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីប្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដោយអនុវត្តស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទមិនត្រូវធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជនឡើយ។ ក្នុងករណីនេះ តតិយជនអាចប្រើប្រាស់សិទ្ធិប្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ច ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ស្របតាមច្បាប់និងនីតិវិធីជាធរមាន។

[៩] សេចក្តីសម្រេចលេខ ០០៧/២៤ សសរ. អ.ដ.ក. ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីបែបបទ និងនីតិវិធីនៃការសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌនៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ដ្យាក្រាមទី៣៖ យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់ អ.ដ.ក.



## (គ) គោលការណ៍គន្លឹះក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ទោះបីជាលក្ខណៈរបស់ការចរចា, ការផ្សះផ្សា, ការសម្រុះសម្រួល, អាជ្ញាកណ្តាល និងទម្រង់ផ្សេងៗទៀតនៃការអនុវត្តតាមបែបយុត្តិធម៌មានភាពខុសប្លែកគ្នា តែការអនុវត្តទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះមួយចំនួន។

**១. ភាពមិនផ្លូវការ៖** ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺមានលក្ខណៈផ្លូវការតិចជាងដំណើរការតាមប្រព័ន្ធតុលាការ។ នៅក្នុងករណីភាគច្រើន នីតិវិធីនៃដំណើរការអាចបត់បែនច្រើន។ ភាពមិនផ្លូវការគឺមានលក្ខណៈទាក់ទាញ និងមានសារៈសំខាន់សម្រាប់ការបង្កើនលទ្ធភាពទទួលបានដំណោះស្រាយវិវាទសម្រាប់ប្រជាពលរដ្ឋ ដែលអាចត្រូវបានបំភិតបំភ័យ ឬមិនមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទផ្លូវការ។ វាមានសារៈសំខាន់ផងដែរសម្រាប់កាត់បន្ថយការពន្យារពេល និងការចំណាយនៃការដោះស្រាយវិវាទ។

**២. គោលការណ៍សមធម៌៖** ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាឧបករណ៍សម្រាប់ការអនុវត្តដើម្បីធានាឱ្យមានសមធម៌ជាជាងការអនុវត្តច្បាប់ទាំងស្រុង។ ករណីនីមួយៗត្រូវបានសម្រេចដោយភាគីទីបី ឬដោយការចរចារវាងភាគីវិវាទទាំងពីរ ដោយផ្អែកលើគោលការណ៍ និងលក្ខខណ្ឌទាំងឡាយដែលជួយធានានូវសមធម៌នៅក្នុងករណីជាក់លាក់ ជាជាងការអនុវត្តលើស្តង់ដារ ឬលក្ខខណ្ឌនៃច្បាប់ដែលត្រូវតែអនុវត្តឱ្យស្មើៗគ្នា។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនអាចត្រូវអនុវត្តឱ្យលើសពីអ្វីដែលច្បាប់មានចែង ឬត្រូវទៅផ្លាស់ប្តូរផ្នែកណាមួយនៃច្បាប់ និងបទដ្ឋានសង្គមនោះឡើយ។ ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវមាននិន្នាការសម្រេចបាននូវការបញ្ចប់វិវាទប្រកបដោយប្រសិទ្ធភាព ដោយឈរលើគោលការណ៍យុត្តិធម៌ដែលមានសណ្ឋានដូចៗគ្នា។ មាត្រា ១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ បានចែងថា ក្នុងកិច្ចដំណើរការសម្រុះសម្រួលផ្សះផ្សាវិវាទ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវផ្តល់ឱ្យភាគីវិវាទនូវឱកាសព្រមព្រៀងគ្នាដោះស្រាយវិវាទដោយសន្តិវិធី និងដោយគ្មានការធ្វើការសម្រេចសេចក្តីដោយបង្ខំណាមួយឡើយ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទអាចផ្តល់មតិជាការវាយតម្លៃអំពីវិវាទ ស្នើនូវដំណោះស្រាយសម្រាប់វិវាទ និងផ្តល់យោបល់អំពីផលវិបាកដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទ។ ប៉ុន្តែនៅក្នុងគ្រប់ការណ៍ទាំងអស់រាល់ដំណោះស្រាយចំពោះវិវាទត្រូវតែគោរពតាមឆន្ទៈយល់ព្រមដោយសេរី និងដោយស្ម័គ្រចិត្តពីភាគីវិវាទ។

**៣. ការចូលរួម និងទំនាក់ទំនងដោយផ្ទាល់រវាងភាគីជម្លោះ៖** លក្ខណៈផ្សេងទៀតនៃប្រព័ន្ធដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គួររួមបញ្ចូលនូវការចូលរួមដោយផ្ទាល់បន្ថែមទៀតដោយភាគីជម្លោះក្នុងដំណើរការនៃការចរចាដោះស្រាយវិវាទ តាមរយៈការសន្ទនាដោយផ្ទាល់ និងការផ្តល់ឱកាសពេញលេញសម្រាប់ការផ្សះផ្សារវាងភាគីវិវាទ និងដោយរក្សាការសម្ងាត់កម្រិតខ្ពស់ ចាប់តាំងពីដំណាក់កាលដំបូង ។

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**Swiss Agency for Development and Cooperation SDC**

DEUTSCHE ZUSAMMENARBEIT

giz

GRAND DUCHY OF LUXEMBOURG

MRLG
MEKONG REGION LAND GOVERNANCE

OXFAM